# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **ខ្មែរ**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Sep-2019, 15:18
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**ចម្លើយតបរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (សំណុំរឿង ០០២/០២)**

---

__ដាក់ដោយ__៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

__ដាក់ជូន__៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele Mwachande MUMBA

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Cécile ROUBEIX

កញ្ញា Dounia HATTABI

លោក Stéphane NICOLAÏ

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS (ព្រះរាជអាជ្ញាបម្រុង)

លោក William SMITH (ព្រះរាជអាជ្ញារង)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញា (ឬ "ម្ចាស់បណ្តឹងសាទុក្ខ") បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០២ ដែលជំទាស់ទៅលើសេចក្តីសន្និដ្ឋានតែមួយគត់របស់អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ")[1]។ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ម្ចាស់បណ្តឹងសាទុក្ខបានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[2]។

២. នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") មិនបានអនុញ្ញាតតាមការស្នើសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី" ឬ "ភាគីចុងចម្លើយ") ក្នុងការគិតរាប់ថិរវេលាកំណត់ចម្លើយទៅកាន់សហព្រះរាជអាជ្ញា ចាប់ត្រឹមពីថ្ងៃភាគីនេះដាក់សារណាបណ្តឹងសាទុក្ខឡើយ។ អង្គជំនុំជម្រះបានអនុញ្ញាតផ្តល់ពេលវេលា ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងលើសាលក្រម[3]។

៣. តាមរយៈចម្លើយតបនេះ វៀរលែងតែមានអំណះអំណាងដែលផ្តល់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន មេធាវីការពារក្តីសូមឆ្លើយទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

៤. ម្ចាស់បណ្តឹងសាទុក្ខបានសម្រេចដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះ ដែលលើកឡើងថាហិង្សាផ្លូវភេទលើជនរងគ្រោះជាបុរស នៅក្នុងក្របខណ្ឌនៃអាពាហ៍ពិពាហ៍ដោយបង្ខំ

---

1 សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ **E465/2/1**។

2 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F50** ("សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា") បានជូនដំណឹងជាភាសាអង់គ្លេស និងជាភាសាខ្មែរ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ បន្ទាប់មកជូនដំណឹងជាភាសាបារាំង នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៩។ មេធាវីការពារក្តីបានទទួលច្បាប់ចម្លងដោយការគួរសមនូវសេចក្តីបកប្រែជាភាសាបារាំងនៅ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។

3 សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F49 កថាខណ្ឌ ២៣-២៨ និង ៣៦។

មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត នោះឡើយ[4]។

៥. បន្ទាប់ពីបរាជ័យក្នុងការបញ្ចុះបញ្ចូលអង្គជំនុំជម្រះ ឱ្យកំណត់និយមន័យទំនើបបំផុតនៃការរំលោភសេពសន្ថវៈ "ដែលមានលក្ខណៈបរិយាប័ន និងគ្មានការរើសអើង ខាងផ្លូវភេទ"[5] សហព្រះរាជអាជ្ញា ក្នុងពេលនេះទៀតសោត ក៏ព្យាយាមបញ្ចុះបញ្ចូលតុលាការកំពូល ថា ហិង្សាផ្លូវភេទលើជនរងគ្រោះបុរស ក្នុងក្របខណ្ឌនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវដាក់ទោសទណ្ឌ ទោះបីជា (I) គ្មានលទ្ធភាពក្នុងការកំណត់លក្ខណៈបទល្មើសនៃអំពើអមនុស្សធម៌ផ្សេងទៀត និង ទោះបីជា (II) មិនមានភស្តុតាងជាក់ច្បាស់គ្រប់គ្រាន់ យ៉ាងណាក្តី។

## I. នត្តិភាពនៃការកំណត់បទល្មើស

៦. ម្ចាស់បណ្តឹងសាទុក្ខបានចោទប្រកាន់អង្គជំនុំជម្រះទាំងទទទឹងទិសថា (១) ពិនិត្យមិនបានគ្រប់គ្រាន់លើធាតុផ្សំភស្តុតាងបទល្មើសនៃអំពើអមនុស្សធម៌ផ្សេងទៀត (២) ដើម្បីអាចធ្វើការវិភាគខុសទៅលើធាតុផ្សំភស្តុតាងនៃបទល្មើសនេះ ដោយមិនគិតដល់គោលការណ៍នីត្យានុកូលភាព នៅក្នុងដំណើរការនីតិវិធីប្រាសចាកពីកាលប្បវត្តិត្រឹមត្រូវ តាមបែបសកម្មជន ច្រើនជាងបែបគតិយុត្តិ។

## ១. ភាពមិនចាំបាច់អន្តរាគមន៍របស់តុលាការកំពូល

៧. ម្ចាស់បណ្តឹងសាទុក្ខបានអះអាងថា អង្គជំនុំជម្រះគួរតែបានពិនិត្យមើលថា តើអំពើដែលរងការចោទប្រកាន់នោះបានបង្កការប៉ះពាល់ធ្ងន់ធ្ងរដល់ភាពថ្លៃថ្នូររបស់មនុស្សដែរឬអត់ ក្នុងករណីមិនបានបង្កឱ្យមានការឈឺចាប់ផ្លូវកាយឬផ្លូវចិត្តធ្ងន់ធ្ងរដល់បុរស[6]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានពិនិត្យលក្ខណៈវិនិច្ឆ័យនេះបានត្រឹមត្រូវហើយ។

---

[4] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១-៣, ៤០ ។

[5] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥ ។

[6] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២, ១៨-២០ ។

៨. ជាក់ស្តែង ដូចការលើកឡើងរបស់សហព្រះរាជអាជ្ញាដែរ អង្គជំនុំជម្រះបានចោទជាសំណួរថា តើអំពើនោះ "អាចកំណត់បានថាជាអំពើហិង្សាផ្លូវភេទដែលមានស្ថានទម្ងន់ធ្ងន់ធ្ងរគ្រប់គ្រាន់ដល់អាចកំណត់បានថាជាអំពើអមនុស្សធម៌ផ្សេងទៀតដែរឬទេ"[7]។ អង្គជំនុំជម្រះបានឆ្លើយថាមិនមែនបែបនោះទេ[8]។ ដោយ "ទទួលស្គាល់" ថាបុរសបានទទួលរងអំពើហិង្សាផ្លូវភេទ "ដែលផ្ទុយពីសេចក្តីថ្លៃថ្នូររបស់មនុស្ស"[9] អង្គជំនុំជម្រះបានពិនិត្យមើល ថាតើអំពើទាំងនោះបានប៉ះពាល់ធ្ងន់ធ្ងរដល់ភាពថ្លៃថ្នូរជាមនុស្សដែរឬទេ។ អង្គជំនុំជម្រះបានសន្និដ្ឋានថាមានការប៉ះពាល់ តែថាការប៉ះពាល់នោះមិនធ្ងន់ធ្ងរគ្រប់គ្រាន់ដល់អាចកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀតនោះឡើយ។

៩. ដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខបានរម្លឹកពីភាពគ្មានគុណវិបត្តិរបស់អង្គជំនុំជម្រះ ដែលមិនចាំបាច់មានអន្តរាគមន៍ពីតុលាការកំពូលឡើយ។ ហេតុដូច្នេះ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ត្រូវតែបដិសេធចោល។

១០. ក្នុងគោលបំណងសម្រាលគុណវិបត្តិរបស់ខ្លួន ក្នុងការផ្តល់ភ័ស្តុតាងពីស្ថានទម្ងន់នៃអំពើរងការចោទប្រកាន់ សហព្រះរាជអាជ្ញាបានជំរុញឲ្យឱ្យតុលាការកំពូលផុងខ្លួនក្នុងអន្លង់នៃគុណវិបត្តិនោះ ដើម្បីបន្ទាប់មក សុំឱ្យតុលាការកំពូលដើរតាមការទាញហេតុផលដែលផ្ទុយពីគោលការណ៍នីត្យានុកូលភាព។

## ២. ការប្រមាថរបស់សហព្រះរាជអាជ្ញាចំពោះគោលការណ៍នីត្យានុកូលភាព

១១. ស្របតាមគោលការណ៍នីត្យានុកូលភាព គ្មាននរណាម្នាក់អាចត្រូវបានផ្តន្ទាទោស ដោយសារអំពើណាមួយ ដែលមិនបង្កើតបានជាបទល្មើស តាមច្បាប់ជាតិ ឬអន្តរជាតិ នៅក្នុងពេលកំពុងប្រព្រឹត្តអំពើនោះឡើយ[10]។ តុលាការកំពូលក៏បានរម្លឹកយ៉ាងដូច្នេះថា៖

---

[7] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦ និង កំណត់សម្គាល់ជើងទំព័រ ៣២។

[8] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧ និង កំណត់សម្គាល់ជើងទំព័រ ៤០ ។

[9] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧ និង កំណត់សម្គាល់ជើងទំព័រ ៤០ ។

[10] មាត្រា ១៥ នៃសកតិកាសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សូមមើលផងដែរ មាត្រា ៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា (« Seuls les faits constitutifs d'une infraction à la date à laquelle ils ont été commis peuvent donner lieu à une condamnation pénale. »)។ សូមមើលផងដែរ ៖សេចក្តីសន្និដ្ឋានបញ្ចប់របស់លោក ខៀវ សំផន (សំណុំរឿង

"ទោះបីជា អ.វ.ត.ក ពឹងផ្អែកយ៉ាងខ្លាំងទៅលើសំអាងហេតុក្នុងការវិភាគ និងការអភិវឌ្ឍច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់តុលាការ *មិនអចិន្ត្រៃយ៍*ក៏ដោយ តែដោយផ្អែកលើគោលការណ៍នីត្យានុកូលភាព និងកិច្ចការពារចង់ភ្ជាប់ជាមួយគោលាករណ៍នេះ អ.វ.ត.ក មានកាតព្វកិច្ចធានាថា លក្ខណៈវិនិច្ឆ័យកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដែលជ្រើសរើសយក ត្រូវបានបញ្ជាក់ដោយច្បាប់នៅក្នុងអំឡុងពេលនៃដែនយុត្តាធិការពេលវេលារបស់ខ្លួន។ ម្យ៉ាងវិញទៀត ជនជាប់ចោទត្រូវទទួលបានការជូនដំណឹងជាមុន និងអាចចូលមើលលក្ខណៈវិនិច្ឆ័យនោះបាន។ បន្ថែមពីលើនេះទៀត តុលាការកំពូលគូសបញ្ជាក់ថា ការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន និងដោយមានសំអាងហេតុអំពីលក្ខណៈវិនិច្ឆ័យទាំងនេះ គឺមិនអាចខ្វះបានដើម្បីធានាធម្មានុរូប និងសេចក្តីសម្រេចរបស់ អ.វ.ត.ក"[11]។

១២. ប៉ុន្តែ ម្ចាស់បណ្តឹងសាទុក្ខគាំទ្រលក្ខណៈវិនិច្ឆ័យមួយដែលកំណត់ធាតុផ្សំភ័ស្តុតាងមួយក្នុងចំណោមធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត ដែលមិនមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (២.១) ហើយបានតស៊ូមតិដើម្បីដាក់ទោសអំពើមួយដែលមិនបង្កជាបទល្មើសក្នុងអំឡុងពេលនៃអង្គហេតុ (២.២)។

## ២.១. គ្មាន<u>ការវិភាគបែបសត្យានុម័តសុទ្ធសាធលើការប៉ះពាល់ដល់ភាពថ្លៃថ្នូរនៅសម័យកាលនៃអង្គហេតុ ដូចពេលបច្ចុប្បន្នឡើយ</u>

១៣. ដោយផ្អែកលើសាលក្រម *Čelebići* ដែលបានចេញកាលពីឆ្នាំ១៩៩៨ នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះ "អាចកំណត់ដោយសត្យានុម័តថាតើអំពើមួយ "ប៉ះពាល់ធ្ងន់ធ្ងរដល់ភាពថ្លៃថ្នូររបស់មនុស្ស" ដោយខ្លួនគ្មានភ័ស្តុតាងនៃការឈឺចាប់ឡើយ"[12]។ ការវិភាគលើធាតុផ្សំជាក់ស្តែងទីពីរនៃបទល្មើស "ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត" មិនធ្លាប់មានទេ នៅក្នុងសម័យកាលនៃអង្គហេតុដែលរងការចោទប្រកាន់ (១៩៧៥-១៩៧៩)។

---

០០២/០២) ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ ធ្វើវិសោធនកម្មនៅ ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ ឯកសារ **E457/6/4/1** កថាខណ្ឌ ៣០០-៣៣០។

[11] សាលដីកា ឌុច ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ **001-F28** កថាខណ្ឌ ៩៧ និង កំណត់សម្គាល់ជើងទំព័រ ១៨៥ ។

[12] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២ និង កំណត់សម្គាល់ជើងទំព័រ ២០។

១៤. ជាក់ស្តែង នៅក្នុងសាលក្រម *Aleksovski* នៅឆ្នាំ១៩៩៩ តុលាការជាន់ទាបសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបំពេញបន្ថែមលើការវិភាគដែលបានធ្វើឡើងក្នុងរឿងក្តី *Čelebići*[13]។ តុលាការបានទទួលស្គាល់ថា វាជា"ការសមស្របក្នុងការ**បញ្ចូល**ធាតុផ្សំសត្យានុម័ត ទៅក្នុងការវាយតម្លៃធាតុផ្សំជាក់ស្តែង"[14]។ តុលាការជាន់ទាបបានអះអាងយ៉ាងជាក់ច្បាស់ថា ការពិនិត្យលើភាពធ្ងន់ធ្ងរនៃការប៉ះពាល់ដល់ភាពថ្លៃថ្នូរជាមនុស្ស នៅតែមានលក្ខណៈអត្តនោម័តសុទ្ធសាធរហូតមកដល់បច្ចុប្បន្ននេះ។

១៥. ស្របតាមគោលការណ៍នីត្យានុកូលភាព ការពិនិត្យលើកម្រិតធ្ងន់ធ្ងរនៃការប៉ះពាល់ដល់ភាពថ្លៃថ្នូរជាមនុស្ស ត្រូវតែវាយតម្លៃជាលក្ខណៈអត្តនោម័ត នៅក្នុងករណីពិសេសនោះ។

១៦. បើក្នុងករណីអស្ចារ្យណាមួយ តុលាការកំពូលនឹងពិចារណាពីភាពចាំបាច់ក្នុងការធ្វើអន្តរាគមន៍ និងវិភាគកម្រិតធ្ងន់ធ្ងរនៃការប៉ះពាល់ដល់ភាពថ្លៃថ្នូរជាមនុស្សនៃធាតុផ្សំជាក់ស្តែងទីពីរ នៃ"អំពើអមនុស្សធម៌ផ្សេងទៀត" ទៅតាមលក្ខណៈវិនិច្ឆ័យសត្យានុម័ត នោះតុលាការកំពូលអាចនឹងអនុវត្តដោយមិនគិតដល់លក្ខណៈវិនិច្ឆ័យអត្តនោម័តនិងដាក់លាក់ចំពោះជនរងគ្រោះដែលរងការចោទប្រកាន់ឡើយ។

១៧. ផ្ទុយពីអ្វីដែលម្ចាស់បណ្តឹងសាទុក្ខបានអះអាង[15] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មិនធ្លាប់បានវាយតម្លៃសត្យានុម័តផ្តាច់មុខទៅលើភាពធ្ងន់ធ្ងរនៃភ័ស្តុតាងជាក់ស្តែងដែលផ្ទុយគ្នាស្រឡះពីដំណើរការនីតិវិធីដែលកំណត់ដើម្បីជាអត្ថប្រយោជន៍ដល់តុលាការខាងលើ។

១៨. ពីព្រោះថា ក្នុងរឿងក្តី *Aleksovski* តុលាការជាន់ទាបបានបញ្ជាក់ដោយឥតស្រពិចស្រពិលថា "ធាតុផ្សំអត្តនោម័តត្រូវសម្រាលដោយកត្តាសត្យានុម័ត បើពុំនោះទេវានឹងបង្កើតភាពអយុត្តិធម៌

---

[13] រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង *Aleksovski,* IT-95-14/1-T, សាលក្រម ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ ("សាលក្រម *Aleksovski*" ) កថាខណ្ឌ ៥២-៥៦។

[14] សាលក្រម *Aleksovski* កថាខណ្ឌ ៥៦ (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[15] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣។

ចំពោះជនជាប់ចោទ៖ ពិរុទ្ធភាពរបស់ជនជាប់ចោទមិនអាស្រ័យទៅលើភាពធ្ងន់ធ្ងរនៃអំពើដែលបាន ប្រព្រឹត្តនោះទេ តែវាអាស្រ័យទាំងស្រុងលើអារម្មណ៍ផ្លូវចិត្តរបស់ជនរងគ្រោះ"[16]។

១៩. ក្នុងន័យនេះ សាលក្រមផ្សេងៗនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានលើកឡើងពីកត្តាទាំងឡាយដែលត្រូវប្រកាន់យក ដើម្បីកំណត់ភាពធ្ងន់ធ្ងរនៃអំពើដែលរងការចោទប្រកាន់។ នៅក្នុងសាលក្រម *Krnojelac* ដែលយោងដោយសហព្រះរាជអាជ្ញា[17] អង្គជំនុំជម្រះសាលាដំបូងបានកំណត់បទចោទនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ដូចខាងក្រោម៖

> "ជាសារជាតិ ការវាយតម្លៃភាពធ្ងន់ធ្ងរនៃអំពើសកម្ម ឬអកម្មណាមួយ មានលក្ខណៈមិនដាច់ខាតឡើយ។ រាល់កាលៈទេសៈអង្គហេតុត្រូវតែរាប់បញ្ចូលទាំងអស់ រួមទាំងសារជាតិនៃអំពើសកម្ម ឬអកម្ម បរិបទ រយៈពេល និង/ឬលក្ខណៈច្រំដែលរបស់អំពើ ឧប្បត្តិហេតុផ្លូវកាយ ផ្លូវចិត្ត និងផ្លូវសីលធម៌ទៅលើជនរងគ្រោះ ព្រមទាំងស្ថានភាពផ្ទាល់ខ្លួនរបស់ជនរងគ្រោះ ជាពិសេសអាយុ ភេទ និងស្ថានភាពសុខភាពរបស់ជនរងគ្រោះ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[18]។

២០. លក្ខណៈវិនិច្ឆ័យជាក់លាក់ទាំងនេះត្រូវបានអះអាងបញ្ជាក់ជាច្រើនលើកច្រើនសា នៅក្នុងប្រយោគដូចៗគ្នា[19]។

២១. ដោយសារតែហេតុផលទាំងនោះ ការពិនិត្យបែបសត្យានុម័តសុទ្ធសាធដែលត្រូវបានស្នើឡើងដោយម្ចាស់បណ្តឹងសាទុក្ខនោះ មានកំហុសឆ្គង និងមិនអាចយកមកធ្វើសំអាងហេតុអំពើការកំណត់អំពើអមនុស្សធម៌ផ្សេងៗទៀត ដោយគ្មានភស្តុតាងពីភាពធ្ងន់ធ្ងរនៃអំពើដែលរងការចោទប្រកាន់។ មធ្យោបាយបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ត្រូវតែទាត់ចោល។

---

[16] សាលក្រម *Aleksovski* កថាខណ្ឌ ៥៦ ។

[17] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់ជើងទំព័រ ៤៥ (នៃកថាខណ្ឌ ១៩) ដែលយោងទៅកថាខណ្ឌ ១៣០ នៃសាលក្រមនោះ។

[18] រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង *Krnojelac*, IT-95-9-T សាលក្រម ថ្ងៃទី ១៥ ខែមិនា ឆ្នាំ២០០២ កថាខណ្ឌ ១៣១ ។

[19] រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង *Simić*, IT-95-9-T សាលក្រម ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ ៧៥ ដែលយោងទៅរឿងក្តី *Vasiljević*, IT-98-32-T សាលក្រម ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ២៣៥ ។

**២.២. <u>ការតស៊ូមតិបែបឱកាសនិយមរបស់សហព្រះរាជអាជ្ញា</u>**

២២. បើតាមម្ចាស់បណ្តឹងសាទុក្ខដែលរម្លឹកដល់យុត្តិសាស្ត្រនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅឆ្នាំ១៩៩៨ "ដោយមិនធ្វើសេចក្តីសន្និដ្ឋានថា ការបង្ខំបុរសឱ្យរួមភេទ បើតាមលក្ខណៈសត្យានុម័ត គឺជាការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាពថ្លៃថ្នូររបស់មនុស្ស អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើគោលការណ៍គ្រឹះនៃច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស រួមមាន "ការការពារភាពថ្លៃថ្នូររបស់បុគ្គល *ទោះបីជាបុរសភេទ ឬភេទស្ត្រីភេទក៏ដោយ*"[20]។

២៣. សហព្រះរាជអាជ្ញាព្យាយាមបែបនេះក្នុងការបំបែក "សតវត្សរ៍នៃបុរេវិនិច្ឆ័យយេនឌ័រ" ដើម្បីរំលេចពីការរងគ្រោះផ្លូវភេទរបស់បុរសក្នុងក្របខណ្ឌនៃរបបកម្ពុជាប្រជាធិបតេយ្យ[21] ដែលបង្កើតបានជាភាពប្រាសចាកពីកាលប្បវត្តិផ្លូវច្បាប់ត្រឹមត្រូវ ជំរុញដោយទស្សនៈនយោបាយសម័យទំនើប។ ការចោទសួរមិនមែនចង់ដឹងថា តើវាជាការសបច្បាប់ឬទេសព្វថ្ងៃនេះ ក្នុងការធ្វើឱ្យវិវត្តផ្នត់គំនិត ប៉ុន្តែចង់កំណត់ថាតើស្ថានភាពផ្លូវច្បាប់បែបណាដែរនៅក្នុងសម័យកាលនៃអង្គហេតុ។

២៤. ជាក់ស្តែង ម្ចាស់បណ្តឹងសាទុក្ខសំអាងថា "ប្រទេសជាច្រើន<u>បានចាប់ផ្តើមទទួលស្គាល់</u>ថា ទស្សនៈ [បុរេវិនិច្ឆ័យ] មិនត្រឹមត្រូវ និងបានពង្រីកក្រមព្រហ្មទណ្ឌរបស់ពួក ដើម្បីបង្កើតនៅក្នុងបទល្មើសព្រហ្មទណ្ឌ នូវស្ថានភាពដែលចារីបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តសកម្មភាពផ្លូវភេទណាមួយ ប្រឆាំងនឹងឆន្ទៈរបស់គាត់ រួមទាំងការបញ្ចូលអង្គជាតិផង ទាំងចំពោះចារី ទាំងចំពោះជនទីបី"[22]។ ដូចសហព្រះរាជអាជ្ញាបានបង្ហាញផងដែរ ច្បាប់ជាតិទាំង១១ ដែលសហព្រះរាជអាជ្ញាបានជំរឿន (ដែលប្រទេសកម្ពុជាមិនទាំងនៅក្នុងនោះផង) បានវិវត្តរហូតដល់ចោទប្រកាន់ករណីបែបនេះ ចាប់តាំងពីឆ្នាំ២00៣ មក (ភាគច្រើនគឺចាប់ពីឆ្នាំ២0១0) គឺស្មើនឹងជាងមួយភាគបួននៃសតវត្សរ៍

---

[20] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤ (មានគូសបន្ទាត់ពីក្រោម នៅក្នុងច្បាប់ដើម) និងកំណត់សម្គាល់ជើងទំព័រ ៦៧។

[21] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨។

[22] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

បន្ទាប់ពីអង្គហេតុកើតឡើង ក្នុងសំណុំរឿង ០០២/០២[23]។ គួរណាស់តែអង្គហេតុសាមញ្ញៗទាំងនេះ ជំរុញឱ្យម្ចាស់បណ្តឹងសាទុក្ខចោទសួរពីភាពជាប់ពាក់ព័ន្ធនៃអំណះអំណាងរបស់ខ្លួនទៅលើចំណុចនេះ។

២៥. លើសពីនោះទៀត បទល្មើសទាំងនោះមិនមែនសុទ្ធតែកំណត់ឡើង ស្របតាមច្បាប់អន្តរជាតិ ហើយមិនអាចស្ថិតនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ ទោះជាយ៉ាងណាក្តី អំណះអំណាងផ្លូវច្បាប់បែបស្មាក់ក់ស្មើររបស់ម្ចាស់បណ្តឹងសាទុក្ខ មិនអាចយកមកធ្វើជាសំអាងក្នុងការចោទប្រកាន់លើការប្រព្រឹត្តិដែលបសនកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែនត្ថិភាពមិនអាចជំទាស់បាននៃភាពអាចដឹងជាមុនបាន។ ផ្ទុយទៅវិញ អំណះអំណាងទាំងនោះគិតតែបកស្រាយបង្ហាញថា ការប្រព្រឹត្តិបែបនេះមិនអាចរងការចោទប្រកាន់សោះឡើយ នៅក្នុងសម័យកាលនៃអង្គហេតុ។

២៦. ដំណើរការនីតិវិធីដែលអនុវត្តដោយសហព្រះរាជអាជ្ញា បង្ហាញអំពីការប្រមាថទាំងស្រុងរបស់ខ្លួនចំពោះលក្ខខណ្ឌនៃអនីត្យានុកូលភាពផ្លូវការអន្តរជាតិ ដែលត្រូវតែបំពេញ ដើម្បីសម្រុះសម្រួលរវាងលក្ខណៈបន្ថែមនៃប្រភេទអំពើអមនុស្សធម៌ផ្សេងៗទៀត និងគោលការណ៍នីត្យានុកូលភាព ដែលតុលាការកំពូលបានរំលឹកថា៖

> "អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការភ្ជាប់ទំនាក់ទំនងរវាង "អំពើអមនុស្សធម៌ផ្សេងទៀត" ជាមួយនឹងអំពើប្រព្រឹត្តិដែលរំលោភបំពានលើសិទ្ធិជាសារវ័ន្តរបស់បុគ្គលដូចបានបញ្ជាក់នៅក្នុងលិខិតូបករណ៍ច្បាប់អន្តរជាតិនោះ គឺជាគោលគំនិតសមស្របមួយត្រង់ថា បន្ថែមទៅលើធាតុផ្សំសត្យានុម័តដែលត្រូវបានកំណត់អត្តសញ្ញាណ តាមរយៈលក្ខណៈវិនិច្ឆ័យស្តីពី *ចរិតលក្ខណៈប្រហាក់ប្រហែលគ្នា (ejusdem generis)* គោលគំនិតនេះបានបង្ហាញលក្ខខណ្ឌតម្រូវនៃអនីត្យានុកូលភាពផ្លូវការជាអន្តរជាតិ និងតាមរបៀបនេះ គឺជាការកម្រិតមួយបន្ថែមទៀតទៅលើសិទ្ធិអំណាចទាំងមូល ក្នុងការបកស្រាយ "អំពើ

[23] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់ជើងទំព័រ ១១៦ (នៃកថាខណ្ឌ ៣៨) ដែលយោងទៅបទល្មើសកើតឡើងនៅអាហ្វ្រិកខាងត្បូង ក្រូអាត ណរវែស្ស អូស្ត្រាលី (វិចតូរីយ៉ា) សឹង្ហបូរី ចក្រភពអង់គ្លេស អាឡឺម៉ង់ រិស្ស៊ី ដាណឺម៉ាក សាធារណរដ្ឋឆែក ហ្វាំងឡង់ ដែលកើតឡើងជាបន្តបន្ទាប់រៀងគ្នាក្នុងឆ្នាំ ២០១៣, ២០១១, ២០០៥, ២០១៩, ២០០៨, ២០០៣, ២០១៣, ២០១២, ២០០៥, ២០០៩, ២០១៥។

អមនុស្សធម៌ផ្សេងទៀត"។ បើទោះបីជាគោលការណ៍នេះហាក់បីដូចជាពុំត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយក្តី ក៏អង្គជំនុំជម្រះតុលាការកំពូលសម្គាល់អំពីអត្ថប្រយោជន៍នៃគោលគំនិតនេះសម្រាប់លក្ខខណ្ឌតម្រូវនៃភាពអាចដឹងជាមុនបាន។ [...] លក្ខខណ្ឌតម្រូវនៃ"អនុត្យានុកូលភាពផ្លូវការ"ត្រូវតែបំពេញដោយការកំណត់អត្តសញ្ញាណនៃការបញ្ជាក់ច្បាស់លាស់នូវសិទ្ធិ និងការហាមឃាត់ដែលមានចែងក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សដែលអនុវត្តបាននៅក្នុងអំឡុងពេលនៃអង្គហេតុ ក្រោមរូបភាព "អំពើអមនុស្សធម៌ផ្សេងទៀត" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)[24]។

២៧. ក្នុងករណីនេះ សហព្រះរាជអាជ្ញាមានបំណងពន្លាតវិសាលភាពនៃការការពារសិទ្ធិមនុស្សជាប្រយោជន៍ដល់ជនរងគ្រោះដែលរងការចោទប្រកាន់ ជាជាងបង្ខំឱ្យមានការពិនិត្យដោយមនសិការទៅលើលិខិតុបករណ៍គតិយុត្តិអន្តរជាតិពាក់ព័ន្ធទៅនឹងសម័យកាលនៃអង្គហេតុ។

២៨. ទោះបីជាម្ចាស់បណ្តឹងសាទុក្ខអះអាងថាមិនមានសច្ចាធារណ៍ក្នុងផ្នែកច្បាប់ ដែលថាបុរសទទួលរងការឈឺចាប់តិចជាងស្ត្រី ពីដោយសារការរួមភេទដោយបង្ខំ[25] យ៉ាងណាក្តី តែស្ត្រីជាកម្មវត្ថុនៃកិច្ចការពារកាន់តែច្រើនឡើងៗចាប់តាំងពីឆ្នាំ១៩៤៩ មក បើធៀបនឹងបុរស។

២៩. អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ បានទទួលស្គាល់យ៉ាងជាក់ច្បាស់ នូវការការពារពិសេសចំពោះស្ត្រីប្រឆាំងនឹងរាល់ការប៉ះពាល់ដល់កិត្តិយស និងជាពិសេសប្រឆាំងនឹងការរំលោភសេពសន្ថវៈ ការបង្ខំឱ្យធ្វើពេស្យាចារ្យ និងការប៉ះពាល់ដល់ភាពខ្មាសអៀន[26]។ លើសពីនោះទៀត សេចក្តីអធិប្បាយនៃអនុសញ្ញាទីក្រុងហ្សឺណែវទី ៤ បានបញ្ជាក់យ៉ាងច្បាស់ថា៖

"គប្បីទទួលស្គាល់ការការពារពិសេសចំពោះបុគ្គលិកលក្ខណៈរបស់ស្ត្រី។ ជាការច្បាស់ណាស់ដែលថា ការគោរពដោយឡែកដែលគេត្រូវផ្តល់ជូនស្ត្រីបន្ថែមពីលើការធានារ៉ាប់រងដែលស្តែងឡើងត្រូវដោយវាក្យខណ្ឌទី ១ ហើយដែលស្ត្រីត្រូវទទួលបានដូចជាបុរសដែរ។ សន្និសីទបានព្យាយាមបញ្ជាក់ជាឧទាហរណ៍ អំពើខ្លះដែលអាចនាំឱ្យប៉ះពាល់ដល់កិត្តិយសស្ត្រី ហើយបានបញ្ជាក់យ៉ាងច្បាស់ពី

---

[24] សាលដីកា សំណុំរឿង ០០២/០១ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** កថាខណ្ឌ ៥៨៤។

[25] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាអាជ្ញា កថាខណ្ឌ ៣៨។

[26] អនុសញ្ញាក្រុងទីហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ទាក់ទិនទៅនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម មាត្រា២៧។

ការរំលោភសេពសន្ថវៈ ការបង្ខំឱ្យធ្វើបេស្យាចារ មានន័យថា ជាការជំរុញតាមរយៈហិង្សា ឬការគំរាមធ្ងន់ធ្ងរឱ្យស្ត្រីណាម្នាក់ប្រព្រឹត្តអំពើអសីលធម៌ ព្រមទាំងរាល់ទម្រង់នៃការប៉ះពាល់ដល់ភាពខ្មាសអៀន។ អំពើទាំងនោះត្រូវបាន និងកំពុងត្រូវបានហាមឃាត់ នៅគ្រប់ទីកន្លែង និងគ្រប់កាលៈទេសៈ ហើយដោយមិនប្រកាន់សញ្ជាតិ ពូជសាសន៍ សាសនា អាយុ ស្ថានភាពគ្រួសារ លក្ខខណ្ឌសង្គម ស្ត្រីត្រូវមានសិទ្ធិដាច់ខាតក្នុងការទទួលបានការគោរព និងការមិនប៉ះពាល់ដល់កិត្តិយស និងការខ្មាសអៀន និយាយឱ្យខ្លី គឺភាពថ្លៃថ្នូរជាស្ត្រី"[27] (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៣០. ដូច្នេះ ទោះបីជាមានការឃោសនាបែបបុរសនិយមរបស់ម្ចាស់បណ្តឹងសាទុក្ខយ៉ាងណាក្តី ការប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់បុរសមិនអាចកំណត់បាន បើគ្រាន់តែផ្អែកតែទៅលើការប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់ស្ត្រីតែប៉ុណ្ណោះទេ[28]។

៣១. លក្ខខណ្ឌអនីត្យានុកូលភាពផ្លូវការមិនត្រូវបានបំពេញ ហើយអំពើដែលរងការចោទប្រកាន់មិនអាចត្រូវកំណត់បានថាជា "អំពើអមនុស្សធម៌ផ្សេងទៀត" នៅសម័យកាលនៃអង្គហេតុ។

៣២. ដូច្នេះ ត្រូវទាត់ចោលអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ។

៣៣. ម៉្យាងវិញទៀត សហព្រះរាជអាជ្ញាមិនបានសម្រេចក្នុងការបកស្រាយពីភាពធ្ងន់ធ្ងរនៃអំពើដែលលើកយកមកពិនិត្យនោះទេ។ ដោយសារហេតុផលនៃលក្ខណៈបន្ថែមនៃបទល្មើសក្រោមទម្រង់អំពើអមនុស្សធម៌ផ្សេងទៀត មេធាវីថា ការពិនិត្យទៅលើកម្រិតការពារក្តីសូមគូសបញ្ជាក់នៃភាពធ្ងន់ធ្ងរ តម្រូវឱ្យមាលក្ខណៈម៉ត់ហ្មត់យ៉ាងខ្លាំងបំផុត។ ភាពម៉ត់ហ្មត់នេះកាន់តែជាហេតុផលសំខាន់ទៅទៀត ពីព្រោះក្នុងសម័យកាលនៃអង្គហេតុ ការបដិសេធសិទ្ធិមនុស្សមិនបង្ហាញពីប្រភេទដូចគ្នា និងកម្រិតនៃភាពធ្ងន់ធ្ងរដូចគ្នាទៅនឹង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការសម្លាប់រង្គាល ការដាក់ឱ្យស្ថិតក្នុងទាសភាព ការជម្លៀស ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ពូជសាសន៍ និងសាសនា។ ទោះជាសព្វថ្ងៃនេះក្តី រាល់ការបំពានលើសិទ្ធិ

---

[27] គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម សេចក្តីអធិប្បាយអំពីអនុសញ្ញាទីក្រុងហ្សឺណែវទី ៤ (Jean S dir.pub. 1958) ទាក់ទងនឹងមាត្រា ២៧ ទំព័រ ២២១។

[28] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាអាជ្ញា កថាខណ្ឌ៤០។

មនុស្ស នៅពុំទាន់ធ្ងន់ធ្ងរគ្រប់គ្រាន់រហូតដល់ចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ[29]។

៣៤. ទោះជាយ៉ាងនោះក្តី ម្ចាស់បណ្តឹងសាទុក្ខព្យាយាមធ្វើយ៉ាងណាភ្ជាប់ទៅនឹងសាលក្រមផ្សេងៗ ដែលយល់ឃើញថាការប៉ះពាល់ធ្ងន់ធ្ងរដល់ភាពថ្លៃថ្នូររបស់មនុស្សត្រូវបានកំណត់ ដោយពិនិត្យលើកាលៈទេសៈអង្គហេតុ[30]។ យ៉ាងណាក៏ដោយ ប្រយោគនេះបង្ហាញថាការរួមភេទដែលរងការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ បង្ហាញនូវកម្រិតធ្ងន់ធ្ងរដែលទាបជាងឆ្ងាយណាស់ ពីរឿងរួមភេទដែលដាក់បង្ហាញចំពោះមុខតុលាការពិសេស។

៣៥. ជាឧទាហរណ៍ នៅក្នុងរឿងក្តី *Bagosora* ដែលស្រង់សេចក្តីដោយសហព្រះរាជអាជ្ញា សាកសពលោកស្រី Agathe Uwilingiyimana ដែលជានាយករដ្ឋមន្ត្រី ស្រាតកាយននល ចំពោះមុខគេឯងគ្រប់គ្នា នៅក្នុងទីស្នាក់នៅជាផ្លូវការរបស់លោកស្រី ជាមួយនឹងស្នាមគ្រាប់បាញ់ពេញខ្លួន និងមានដបដែលជាប់បញ្ចូលក្នុងយោនី[31]។ អង្គហេតុទាំងនេះ គឺពិតជាមិនអាចប្រៀបផ្ទឹមបាននឹងអង្គហេតុនៅក្នុងសំណុំរឿង ០០២/០២ បានឡើយ ហើយការប្រៀបធៀបក៏មិនអាចយកមកថ្លឹងថ្លែងលើសច្ចធារណ៍នៃភាពធ្ងន់ធ្ងរនៃអំពើ ដែលរងការចោទប្រកាន់ពីសហព្រះរាជអាជ្ញាបានសោះឡើយ។ ម៉្យាងទៀត ដោយពិនិត្យលើកាលៈទេសៈនៃហេតុការណ៍នោះ គេអាចសង្កេតឃើញថាស្ថានភាពនោះមិនមានធាតុផ្សំណាមួយដែលអាចបំភ្លឺបញ្ហាទាក់ទងនឹងការផ្សំដំណេក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានឡើយ[32]។

---

[29] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Popović* និងបក្សពួក សំណុំរឿងលេខ IT-05-88-A សាលដីកា ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៧៦១៖ « *The Trial Chamber correctly stated that "[n]ot every denial of a human right is serious enough to constitute a crime against humanity"* ។

[30] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាអាជ្ញា កថាខណ្ឌ ២៣ កំណត់សម្គាល់ជើងទំព័រ ៥៩ ដល់ ៦៥។

[31] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាអាជ្ញា កថាខណ្ឌ ២៣ យោងទៅរឿងក្តី *Bagosora* សំណុំរឿងលេខ ICTR-98-41-T សាលក្រម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ (សាលក្រម *Bagosora*) កថាខណ្ឌ ៧០៥។

[32] ម៉្យាងទៀត គួរកត់សម្គាល់ផងដែរថា សាលក្រម Bagosora បានយោងយ៉ាងជាក់ច្បាស់ទៅនឹងរឿងក្តី *Niyitegeka* ដោយផ្អែកលើសេចក្តីជូនដំណឹងពិរុទ្ធភាព និងដោយហេតុផលបញ្ជាក់អង្គហេតុប្រហាក់ប្រហែលគ្នា។ សាលក្រម *Bagosora* កំណត់សម្គាល់ជើងទំព័រ ២៣៧២ (ដែលយោងទៅរឿងក្តី *Niyitegeka* សំណុំរឿងលេខ ICTR-96-14-T សាលក្រម ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ៤៥៩-៤៦៧)៖ នៅក្នុងរឿងក្តី"*Niyitegeka* ជនជាប់ចោទត្រូវបានគេរកឃើញថាជាពិរុទ្ធជននៃ

៣៦. ទន្ទឹមនឹងនោះ ជាឧទាហរណ៍ ដូចក្នុងរឿងក្តី *Kunarac* ម្ចាស់បណ្តឹងសាទុក្ខ បានអានសាលក្រមតែមួយផ្នែកប៉ុណ្ណោះ។ ផ្ទុយពីការចោទប្រកាន់របស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែផ្អែកទៅលើការដែលជនរងគ្រោះត្រូវបានបង្ខំឱ្យរាំស្រាតនៅលើតុប៉ុណ្ណោះទេ[33]។ ពីព្រោះថាភាពធ្ងន់ធ្ងរនៃការធ្វើឱ្យអាម៉ាស់ ត្រូវបានកំណត់ដោយសារតែមានបណ្តុំអំពើជាច្រើនដែលធ្វើឡើងប្រឆាំងនឹងជនរងគ្រោះទាំងអស់នោះ[34]។

៣៧. លើសពីនោះ កត្តាអាយុ (១៥ ឆ្នាំ) និងកត្តាភេទស្រីនៃយុវតីទាំងនោះ ត្រូវបានយកទៅប្រើជាសន្ទស្សន៍បន្ថែម ដើម្បីរក្សានូវភាពធ្ងន់ធ្ងរក្នុងការប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់ពួកគេ[35]។ នីតិវិធីនេះក៏ត្រូវបានពន្យល់ច្បាស់នៅក្នុងសាលក្រមផ្សេងៗនាពេលក្រោយៗមកនៃតុលាការខាងលើ[36]។

៣៨. ដូចគ្នានេះដែរ ម្ចាស់បណ្តឹងសាទុក្ខបានខកខានមិនបានកត់សម្គាល់លក្ខណៈវិនិច្ឆ័យចាំបាច់ទាំងនេះសម្រាប់ធ្វើការបកស្រាយលើភាពធ្ងន់ធ្ងរនៃអំពើដែលរងការចោទប្រកាន់ តែបែរជាទាញអត្ត

---

អំពើអមនុស្សធម៌ផ្សេងៗទៀត ដោយសារតែបានប្រមាថប្រមាប់ភេទរបស់បុរសម្នាក់ និងបានបញ្ចូលឈើស្រួចក្នុងយោនីស្ត្រីម្នាក់បន្ទាប់ពីបានសម្លាប់ជនរងគ្រោះទាំងនោះ។"

[33] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាអាជ្ញា កថាខណ្ឌ ២៣។

[34] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Kunarac* សំណុំរឿងលេខ IT-96-23-T & IT-96-23/1-T សាលក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០០១ (សាលក្រម *Kunarac*) កថាខណ្ឌ ៧៨១៖ ដ្ឋានថាអង្គជំនុំជម្រះសាលាដំបូងបានសន្និ"Radomir Kovac បានប្រព្រឹត្តដោយគ្មានហេតុផលទៅលើស្ត្រីពីររូប ដោយធ្វើបាបពួកគេ និងធ្វើឲ្យពួកគេអាម៉ាស់ ក៏ដូចជាចំពោះជនរងគ្រោះដទៃទៀត ដោយប្រើប្រាស់ឥទ្ធិពលសិទ្ធិកាន់កាប់ដីធ្លីទៅលើពួកគេ ទៅតាមទំនើងចិត្តរបស់ខ្លួន។ Kovac បានបង្ខំពួកនាងតាមរបៀបដូចគ្នានោះ។ (...) អង្គជំនុំជម្រះសាលាដំបូងក៏ជឿជាក់ផងដែរថា Kovac បានប្រើប្រាសអំណាចរបស់ខ្លួនដោយចេតនាទៅលើយុវតី ហើយថា <u>ភាគច្រើននៃអំពើដែលបានប្រព្រឹត្តគឺជាប្រភពនៃការធ្វើឱ្យអាម៉ាស់</u> គឺជាអ្វីដែលជនជាប់ចោទមិនអាចមិនដឹងឮនោះទេ "(យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[35] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាអាជ្ញា កថាខណ្ឌ ២៣។ សាលក្រម *Kunarac* កថាខណ្ឌ ៧៧៣៖ ជនជាប់ចោទ" *Radomir Kovac* ដឹងច្បាស់ណាស់ថា បើខ្លួនបង្ខំស្ត្រីទាំងបីរូបឲ្យឈរស្រាតនៅលើតុ ក្រោមក្រសែភ្នែករបស់ខ្លួន គេបានបង្ខំនារីទាំងនោះឲ្យធ្វើអ្វីមួយដ៏សែនលំបាក និងគួរឲ្យអាម៉ាស់ <u>លើសពីនោះទៀត ពួកនាងសុទ្ធតែនៅក្មេងៗ</u>" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[36] សូមមើលខាងលើ កំណត់សម្គាល់ជើងទំព័រ ១៨ និង ១៩។

ប្រយោជន៍ពីការទាញសេចក្តីសន្និដ្ឋានជាទូទៅមួយ ដែលមិនមានភាពពាក់ព័ន្ធនឹងអង្គហេតុ និងអង្គច្បាប់។ ហេតុដូច្នេះ អំណះអំណាងរបស់សហព្រះរាជអាជ្ញាត្រូវតែបដិសេធចោល។

៣៩. **ជាសេចក្តីសន្និដ្ឋាន** ក្នុងអង្គច្បាប់ អំពើដែលរងការចោទប្រកាន់ទាក់ទងនឹងការរួមភេទដោយបង្ខំលើជនរងគ្រោះបុរស មិនមែនជាបទល្មើសនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ឡើយ។ ក្រៅពីការវិភាគគតិយុត្តិដែលមានកំហុសឆ្គង សហព្រះរាជអាជ្ញាខំប្រឹងលាក់បាំងនូវភាពទទេនៃធាតុផ្សំភ័ស្តុតាងដែលអាចបកស្រាយបង្ហាញអំពីផលប៉ះពាល់ និងភាពធ្ងន់ធ្ងរនៃបទល្មើសដែលរងការចោទប្រកាន់ចំពោះជនរងគ្រោះតាមសន្មត។

## II. នត្ថិភាពនៃភ័ស្តុតាង

៤០. ដោយមិនអាចបង្ហាញភ័ស្តុតាងអំពីផលប៉ះពាល់ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើបុរស ម្ចាស់បណ្តឹងសាទុក្ខស្តីបន្ទោសដល់អង្គជំនុំជម្រះថាមានចំណាត់ការផ្ទុយគ្នាមិនសមស្របចំពោះភ័ស្តុតាង និងការរកឃើញរបស់ខ្លួនផ្ទាល់ ក៏ដូចជាមិនអើពើនឹង "ផ្នែកយ៉ាងធំ" នៃភ័ស្តុតាងពាក់ព័ន្ធនៅក្នុងសំណុំរឿង។ អង្គជំនុំជម្រះ "បានមើលរំលងភ័ស្តុតាងផ្ទាល់ដែលពាក់ព័ន្ធជាក់ស្តែងទៅនឹងការវិភាគ" និង "បានទាត់ចោលភ័ស្តុតាងប្រយោលទាំងអស់ ឬបានផ្តល់ទម្ងន់តិចតួចមិនមានសមាមាត្រ"[37]។

៤១. ផ្ទុយទៅវិញ គួរកត់សម្គាល់ថា គ្មានភ័ស្តុតាងផ្ទាល់ណាមួយអាចឱ្យកំណត់ចរិតលក្ខណៈឧក្រិដ្ឋកម្មបានឡើយ (១)។ ភ័ស្តុតាងប្រយោលមួយចំនួន ដែលម្ចាស់បណ្តឹងសាទុក្ខបានលើកឡើង មិនមានភាពពាក់ព័ន្ធ និងគ្មានតម្លៃជាភ័ស្តុតាងទាល់តែសោះ (២)។ ជាចុងក្រោយ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះថាអង្គហេតុមិនបង្កើតបានជាឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត មិនផ្ទុយនឹងការរកឃើញផ្សេងទៀតរបស់អង្គជំនុំជម្រះឡើយ (៣)។

### ១. នត្ថិភាពនៃភ័ស្តុតាងផ្ទាល់

[37] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២ កថាខណ្ឌ ២៥-៣៧ កថាខណ្ឌ ៣៩។

៤២. គួរឱ្យភ្ញាក់ផ្អើលណាស់ ដែលគ្មានសក្ខីកម្មណាមួយនៅក្នុងសវនាការអាចឱ្យកំណត់ចរិតលក្ខណៈឧក្រិដ្ឋកម្មបាន (១.១) រួមទាំងភ័ស្តុតាងផ្ទាល់ពីរ ដែលម្ចាស់បណ្តឹងសាទុក្ខបានលើកឡើង (១.២)។

## ១.១. អលទ្ធភាពក្នុងការកំណត់ចរិតលក្ខណៈឧក្រិដ្ឋកម្ម ដោយផ្អែកលើសក្ខីកម្មនៅក្នុងសវនាការ

៤៣. ពេលជំនុំជម្រះក្តី បុរសជាច្រើន (សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី) បានផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងចំណោមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ១២ នាក់ ដែលមកបង្ហាញខ្លួន ក្នុងវគ្គសវនាការស្តីពីការរៀបអាពាហ៍ពិពាហ៍ បុរស ៤ នាក់ ត្រូវបានស្តាប់ចម្លើយ (១.១.១)។ ក្នុងចំណោមបុរស ៥៥ នាក់ផ្សេងទៀត ដែលត្រូវបានស្តាប់ចម្លើយអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងវគ្គផ្សេងៗទៀត បុរស ៣ នាក់ បានឆ្លើយថាពួកគេផ្ទាល់បានរៀបការមិនសមតាមបំណងរបស់ខ្លួន (១.១.២)។ គ្មានសក្ខីកម្មណាមួយអាចបង្ហាញឱ្យឃើញអំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត ដោយសារតែការរួមដំណេកដោយបង្ខំឡើយ។

### ១.១.១. បុរសដែលបានផ្តល់សក្ខីកម្ម ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍

៤៤. ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ អង្គជំនុំជម្រះបានស្តាប់ចម្លើយបុរស ៤ នាក់ ដែលសុទ្ធតែជាដើមបណ្តឹងរដ្ឋប្បវេណី រួមមាន យស ផល, ស៊ូ សុធារី, សេង សឿន និង កុល ណែម[38]។ អង្គជំនុំជម្រះបានលើកឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ២ នាក់ដំបូង (យស ផល និង ស៊ូ សុធារី) នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនថា អង្គជំនុំជម្រះមិនអាចឈានដល់ការសម្រេចមួយស្តីពីភាពធ្ងន់ធ្ងរនៃការឈឺចាប់ ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀតបានឡើយ[39]។

---

[38] អង្គជំនុំជម្រះបានស្តាប់ចម្លើយបុគ្គល ១២ នាក់ ក្នុងនោះ មានសាក្សី ២ នាក់ ដើមបណ្តឹងរដ្ឋប្បវេណី ៩ នាក់ លើអង្គហេតុ និងដើមបណ្តឹងរដ្ឋប្បវេណី ៣ នាក់ លើការឈឺចាប់ដែលបានទទួលរង។

[39] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧។

៤៥. សហព្រះរាជអាជ្ញាបានបង្ខំចិត្តទទួលស្គាល់ថា ការមិនពិចារណារបស់អង្គជំនុំជម្រះទៅលើសក្ខីកម្មរបស់ យស ផល គឺពិតជាត្រឹមត្រូវ។ ជាក់ស្តែង ការឈឺចាប់ដែលគាត់បានលើកឡើងពុំមានទំនាក់ទំនងអ្វីទាល់តែសោះជាមួយនឹងការរួមដំណេក[40] ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់អំពីរបៀបនៃការរីកលូតលាស់មនោសញ្ចេតនាជាប្តីប្រពន្ធរបស់គាត់[41]។

៤៦. ស៊ូ សុធារី ជាភេទទីបី បានផ្តល់សក្ខីកម្មថា ការរៀបការរបស់គាត់ជាមួយស្ត្រីម្នាក់ និងការរួមដំណេកដោយបង្ខំ បានកើតឡើង ដោយសារគាត់ជាភេទទីបី ដែលជាមូលហេតុពិតប្រាកដនៃការបៀតបៀនផ្លូវភេទលើរូបគាត់[42]។ ក្នុងរឿងរ៉ាវខុសប្លែកពីគេនេះ គាត់បានបញ្ជាក់ថា គាត់មិនបានរួមដំណេកទេ ក្នុងរយៈពេលរាប់សប្តាហ៍ក្រោយពីរៀបការរួច[43]។ ជាពិសេស លក្ខខណ្ឌដែលគាត់បានលើកឡើងពាក់ព័ន្ធនឹងការរួមដំណេកនេះ គឺក្រោយពីប្តីប្រពន្ធគូនេះបានផឹកស្រាដែលផ្តល់ដោយប្រធានភូមិ ដែលស្រឡាញ់រាប់អានដើមបណ្តឹងរដ្ឋប្បវេណីទុកដូចជាបងប្អូន ក៏មិនអាចឱ្យសន្និដ្ឋានថាមានហិង្សាដែលមានចរិតលក្ខណៈជាឧក្រិដ្ឋកម្ម ដែលអាចចាត់ទុកជាអំពើអមនុស្សធម៌ផ្សេងទៀតបានឡើយ[44]។ ដូច្នេះ អង្គជំនុំជម្រះមិនបានប្រព្រឹត្តកំហុសទេ ត្រង់ចំណុចនេះ។

៤៧. សេង សឿន ដែលបានរៀបការជាមួយប្អូនជីដូនមួយរបស់ប្រធានគាត់ តាមការស្នើពីប្រធាននោះមិនបានបង្ហាញការឈឺចាប់ ឬផលប៉ះពាល់ជាយថាហេតុ ដោយសារតែការរៀបការតាមការផ្សំផ្គុំ

---

[40] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧ កំណត់សម្គាល់ជើងទំព័រលេខ ៨៣។ ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងអំពីវិប្បដិសារី ពីព្រោះមិនអាចរៀបការជាមួយគូដណ្តឹងរបស់ខ្លួនតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យបាន ដោយសារតែគាត់មានគ្រួសារពាក់ព័ន្ធនឹងរបប លន់ នល់។ យស ផល៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ប្រហែលម៉ោង [10.59.05]។ ផ្ទុយទៅវិញ គាត់បញ្ជាក់ថា "គ្រាន់តែមានៗអ្នកខ្លះថាគូដណ្តឹងគេ វាមានប្រវត្តិរូបល្អ" ឯកសារ **E1/464.1** ប្រហែលម៉ោង [10.39.30]។

[41] យស ផល៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ប្រហែលម៉ោង [10.52.32]។

[42] ស៊ូ សុធារី៖ ប្រតិចារឹក ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/463.1** ក្រោយម៉ោង [14.00.55] "បង្ខំរៀបការ [...] គេមើលងាយ មានសព្វគ្រប់ទាំងអស់ លើការបៀតបៀននូវផ្លូវភេទដែលខ្ញុំជាប្រភេទទី ៣"។

[43] ស៊ូ សុធារី៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ក្រោយម៉ោង [15.24.14] "យប់ដំបូងហ្នឹង គឺអត់បានរួមដំណេកជាមួយប្រពន្ធដែរ [...] ថាសឹងតែថារាប់អាទិត្យហើយ។ [...] អ្នកឯងបានដេកនៅ? ខ្ញុំឆ្លើយថាដេកហើយៗ អញមិនជឿអ្អែងទេ! អ្អែងប្រុសមិនប្រុស ស្រីមិនស្រីអ៊ីចឹង ទៅដេកជាមួយគ្នាកើតយ៉ាងម៉េច?"។

[44] ស៊ូ សុធារី៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** មុនម៉ោង [15.27.02]។

ឬការរួមដំណេកទេ។ គាត់មិនបានលើកឡើងអំពីមនោសញ្ចេតនាស្នេហា និងការបង្ខិតបង្ខំទេ[45]។ ម្យ៉ាងវិញទៀត គាត់ក៏មិនបាននិយាយអំពីការរៀបការរបស់គាត់ទាល់តែសោះ ក្នុងសវនាការថ្លែងអំពីទុក្ខសោក[46]។

៤៨. កុល ណែម ជាដើមបណ្ដឹងរដ្ឋប្បវេណី បានឆ្លើយថា គាត់ត្រូវយល់ព្រមរៀបការតាមការផ្សំផ្គុំ ទោះជាគាត់មានគូដណ្ដឹងពីមុនទៅហើយក្ដី[47]។ ក្រោយពីគិតអស់បីថ្ងៃ គាត់បានសម្រេចចិត្តរួមដំណេកពីព្រោះមានគេតាមដាន[48]។ ប៉ុន្តែ ពេលគាត់ថ្លែងអំពីការឈឺចាប់ គាត់និយាយថា៖ "ខ្ញុំឈឺចាប់ដែរ។ ក៏ប៉ុន្តែបានខ្ញុំមកប្ដឹងជាមួយលោកដូចថាមេធាវីឱ្យជួយ <u>តើគិតយ៉ាងម៉េចធ្វើបាបខ្ញុំ? ធ្វើបាបប្រពន្ធខ្ញុំទាល់តែអត់មានកូនមានចៅ ហើយមិនមែនត្រឹមតែប្រពន្ធខ្ញុំទេ</u> កូនគេខ្លះៗទៀត [...]"[49] (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ត្រង់ចំណុចនេះទៀត ទំនាក់ទំនងផ្លូវភេទមិនត្រូវបានបង្ហាញថាជាអំពើហិង្សា ឬមូលហេតុនៃការឈឺចាប់ទេ។

៤៩. គួរកត់សម្គាល់ថា រឿងរ៉ាវទាំងនេះ ដែលជាស្នូលនៃបទពិសោធន៍របស់បុរស ក្នុងក្របខ័ណ្ឌនៃវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ មិនអាចឱ្យសន្និដ្ឋានថា ទំនាក់ទំនងផ្លូវភេទរវាងប្ដី និងប្រពន្ធ ដែលបុរសបានទទួលរង ឈានដល់កម្រិតឈឺចាប់ធ្ងន់ធ្ងររហូតអាចឱ្យកំណត់ជាអំពើអមនុស្សធម៌ផ្សេងទៀតបានឡើយ។

### ១.១.២. <u>បុរសដែលបានផ្ដល់សក្ខីកម្ម ក្នុងវគ្គផ្សេងទៀតក្រៅពីវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍</u>

---

[45] សេង សឿន៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/465.1** មុនម៉ោង [15.26.31] "ស៖ បាទ អ៊ីចឹង ការរួមរស់ជាមួយគ្នា លោកជាមួយប្រពន្ធលោកហ្នឹង គឺមានការបង្ខិតបង្ខំ ភាគីណាបង្ខិតបង្ខំគ្នាទៅវិញទៅមក ឬមួយក៏ជាការស្ម័គ្រចិត្តទាំងសងខាង? ឆ៖ រឿងខ្ញុំមិនមែនជាការស្រឡាញ់គ្នា ក៏មិនបាន មិនដែរ។ ហើយថាគេបង្ខំ ក៏មិនៗដែរ [...] បីសាអីណោះ ឱ្យយកប្រពន្ធហ្នឹង បានសួរច្រើនដងពេក យកក៏យកទៅ"។

[46] សេង សឿន៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ក្រោយម៉ោង [11.37.55]។

[47] កុល ណែម៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** មុនម៉ោង [14.27.45] "ខ្ញុំពិបាកផ្លូវចិត្ត បានខ្ញុំដាក់ពាក្យប្ដឹងមកតុលាការ ដើម្បីឱ្យជួយនូវផ្លូវចិត្តខ្ញុំខ្លះ ហ្នឹងហើយខ្ញុំនៅខឹងដដែល ប៉ុន្តែ ប្រពន្ធហ្នឹង អត់ៗលែងទេ ខ្ញុំអត់លែងដែរ នៅតែយក ព្រោះខ្ញុំគិតវែងថា បើម៉ែឯងក៏ស្រី គេក៏ស្រី ខ្ញុំគិតក្នុងខ្លួនខ្ញុំអ៊ីចឹង"។

[48] កុល ណែម៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** មុនម៉ោង [15.08.56]។

[49] កុល ណែម៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** មុនម៉ោង [14.35.14]។

៥០. ក្នុងចំណោមបុរស ៥៥ នាក់ផ្សេងទៀត ដែលបានផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានតែបុរស ៣ នាក់ប៉ុណ្ណោះ ដែលបានឆ្លើយថាបានរៀបការខុសមិនសមតាមបំណងរបស់ខ្លួន គឺ មាន លឿយ (ដើមបណ្តឹងរដ្ឋប្បវេណី អំពីផលប៉ះពាល់ និងឧក្រិដ្ឋកម្ម) ម៉ី សារឿន (ដើមបណ្តឹងរដ្ឋប្បវេណី) និង ជាល ជឿន (សាក្សី)[50]។

៥១. មាន លឿយ ដែលបានរៀបការតាមការផ្សំផ្គុំពីអង្គការ បានចាត់ទុកការស្រឡាញ់គ្នាទៅវិញទៅមកជាកាតព្វកិច្ចផ្សារភ្ជាប់នឹងការរៀបអាពាហ៍ពិពាហ៍[51]។ សំខាន់ជាងនេះទៅទៀត គាត់មិនបានលើកឡើងទាល់តែសោះអំពីលក្ខណៈបង្ខិតបង្ខំនៃការរួមភេទ ពីព្រោះគាត់បានឆ្លើយថា គាត់ និងប្រពន្ធគាត់ព្រមរួមដំណេកជាមួយគ្នា[52]។ ម្យ៉ាងវិញទៀត ការថ្លែងអំពីការឈឺចាប់របស់គាត់និយាយដល់ការស្លាប់របស់ស្ត្រីម្នាក់នេះ ដែលគាត់មានមនោសញ្ចេតនាជ្រាលជ្រៅបំផុត៖ "បាទ ចំពោះខ្ញុំ មិនដែលមានអារម្មណ៍សប្បាយចិត្តទេ មានតែអារម្មណ៍សោកសង្រេង ព្រោះការស្តាយអាល័យ ដែលប្រពន្ធដែលធ្លាប់បានរស់នៅជុំគ្នា ទោះតិចក្តីច្រើនក្តី ក៏ជាប្រពន្ធដែរ"[53]។

៥២. ម៉ី សារឿន បានបញ្ជាក់ថា គាត់បានរៀបការជាមួយស្ត្រីម្នាក់ដែលមិនធ្លាប់ស្គាល់គ្នា និងមិនបានប្រកែក ដោយសារតែគាត់មានឋានៈជាអតីតទាហានភូមិភាគបូព៌ា។ ផ្ទុយទៅវិញ នៅក្នុងរឿងរ៉ាវរបស់គាត់ មិនមានចំណុចណាមួយអាចឱ្យសន្និដ្ឋានថាគាត់បានទទួលរងអំពើហិង្សាផ្លូវភេទនោះទេ ពីព្រោះគាត់បានឆ្លើយថា៖ "ការរស់នៅក្នុងយប់ទីមួយហ្នឹង ក៏ខ្ញុំមិនបានជាប៉ះពាល់អីដែរ នៅយប់ទី

---

[50] បុរស ១៦ នាក់ផ្សេងទៀត បានផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ដោយគ្មានការបង្ខិតបង្ខំ ពោលគឺតាមការស្ម័គ្រចិត្ត ឬតាមការផ្សំផ្គុំពីឪពុកម្តាយ ឬមិនបង្កប់ន័យថាបង្ខំ៖ អ៊ុំ ជី, ឈុំ សេង, ឈុយ ហ៊ុយ, សុះ ពន់យ៉ាមីន, សេង ស្រ៊ុន, ហ៊ឹម ម៉ាន, សុះ រំលី, ឌុច, យន់ ប៊ីន, ហួន ជឿម, ជិន គីមថុង, ជិន សារឿន, សេង លីថេង, ម៉ាក ឈឿន, មាស សឿន, ជួន ធី។

[51] មាន លឿយ៖ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ក្រោយម៉ោង [14.13.46]។ "ឆ៖ បាទ ចំពោះខ្ញុំ ដោយសារតែខ្ញុំបានសិក្សាខាងគុណធម៌ច្រើន អ៊ីចឹង ទោះបីល្អអាក្រក់យ៉ាងម៉េច ចាប់ដៃគ្នាហើយត្រូវតែស្រឡាញ់" ឯកសារ **E1/340.1** ក្រោយម៉ោង [14.17.45] ។

[52] មាន លឿយ៖ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ក្រោយម៉ោង [14.17.45] "ស៖ បន្ទាប់ពីថ្ងៃរៀបការហើយ តើលោក និងប្រពន្ធលោក យល់ព្រមជាមួយគ្នាក្នុងការរួមដំណេកជាប្តីប្រពន្ធទេលោក? ឆ៖ បាទ យើងព្រម"។

[53] មាន លឿយ៖ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** មុនម៉ោង [14.55.04]។

ពីរ ក៏អត់បានប៉ះពាល់ដែរ រហូតទាល់តែដល់ទៅថ្ងៃយូរខាងមុខទៀត ទើបនឹងហៅថា បានមានចិត្តស្រឡាញ់ មានចិត្តអាណិត”[54]។

៥៣. ជាល ជឿន និយាយថា លែងប៉ាន់ជំទាស់នឹងការរៀបការដែលអង្គការបានសម្រេច ដោយសារខ្លាចមានរឿងដល់ខ្លួន ក្រោយពីបានប្រកែកម្តងរួចមកហើយ[55]។ ក៏ប៉ុន្តែ គាត់មិនបានបញ្ជាក់ទាល់តែសោះអំពីបញ្ហាជាក់លាក់នៃការរួមដំណេក។ ខណៈដែលសហព្រះរាជអាជ្ញាអាចសួរដេញដោលគាត់លើប្រធានបទនេះបាន បែរជាមិនសួរទៅវិញ។ ដូច្នេះ គេមិនអាចផ្អែកលើរឿងរ៉ាវរបស់គាត់ដើម្បីសន្និដ្ឋានថាមានផលប៉ះពាល់ជាយថាហេតុនៃអំពើហិង្សាផ្លូវភេទនោះឡើយ។

៥៤. ដូច្នេះ ច្បាស់ណាស់ថា ភស្តុតាងផ្ទាល់បានមកពីសក្ខីកម្មរបស់បុរសក្នុងសវនាការ មិនគ្រប់គ្រាន់អាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា មានអត្ថិភាពនៃការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ឬផលប៉ះពាល់ ឬការទទួលរងការឈឺចាប់ជាយថាហេតុដោយបុរស ដោយសារតែអំពើហិង្សាផ្លូវភេទនោះឡើយ។ ប្រឈមនឹងភាពទន់ខ្សោយនៃភស្តុតាងទាំងនេះ សហព្រះរាជអាជ្ញាបានប៉ុនប៉ងស្វែងរកកំហុសរបស់អង្គជំនុំជម្រះ ដោយលើកឡើងនូវភស្តុតាងចំនួនពីរផ្សេងទៀត ដែលមិនត្រឹមតែមិនមែនជាភស្តុតាងផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងមិនគ្រប់គ្រាន់ឱ្យបង្ហាញអំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទៀតផង។

## ១.២. <u>អលទ្ធភាពក្នុងការកំណត់ចរិតលក្ខណៈឧក្រិដ្ឋកម្ម ដោយផ្អែកលើភស្តុតាងផ្ទាល់ចំនួនពីរដែលម្ចាស់បណ្តឹងសាទុក្ខបានលើកឡើង</u>

[54] មុី សាវឿន៖ ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/459.1** មុនម៉ោង [14.14.05]។ នៅយប់ដំបូង គាត់បានប្រាប់ប្រពន្ធថា គ្មានជម្រើសអ្វីក្រៅពីគោរពតាមការណែនាំរបស់អង្គការទេ ឯកសារ **E1/459.1** ក្រោយម៉ោង [14.20.44]។ មិនមានការលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ទេ ក្នុងការថ្លែងអំពីព្យសនកម្ម នៅចុងបញ្ចប់នៃសវនាការ ឯកសារ **E1/459.1** ក្រោយម៉ោង [15.52.28]។ “[...] បើយើងមិនរស់នៅជាមួយគ្នាទេ គេនឹងមានៗផែនការល្បិចកលយ៉ាងម៉េចទេ ខ្ញុំមិនប៉ាន ប្រឆាំងដែរ” ឯកសារ **E1/459.1** មុនម៉ោង [14.14.05]។ ឪពុកម្តាយខាងស្រីមានវត្តមានក្នុងពេលរៀបការ ហើយនាងបានណែនាំគាត់ឱ្យគ្រួសារស្គាល់ រួចហូបបាយរួមគ្នា ឯកសារ **E1/459.1** ក្រោយម៉ោង [15.47.41]។

[55] ជាល ជឿន៖ ប្រតិចារឹក ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/484.1** ក្រោយម៉ោង [10.02.55]។ ឆ្លើយនឹងសំណួររបស់សហព្រះរាជអាជ្ញា៖ “ខ្ញុំអត់ប៉ាននិយាយ ព្រោះឮសួរថាពាក្យអង្គការកំណត់មួយម៉ាត់ គឺខ្លាច បើសិនជាខ្ញុំមិនទទួល ខ្ញុំខ្លាចងាប់អីចឹង ខ្ញុំនៅស្ងៀមទៅ” ឯកសារ **E1/484.1** មុនម៉ោង [10.04.52]។

៥៥. ដើម្បីគាំទ្រដល់អំណះអំណាងភាន់ច្រឡំរបស់ខ្លួន ម្ចាស់បណ្ដឹងសាទុក្ខសំអាងលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន (១.២.១) និងយោបល់របស់អ្នកជំនាញ Kasumi NAKAGAWA (១.២.២)។

## ១.២.១. ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន

៥៦. បើតាមម្ចាស់បណ្ដឹងសាទុក្ខ សក្ខីកម្មរបស់ អែម អឿន គឺជា "ភ័ស្តុតាងពាក់ព័ន្ធផ្ទាល់" ដែលរំលេចចេញនូវការឈឺចាប់របស់បុរសដែលជា "ជនរងគ្រោះនៃការរួមភេទដោយបង្ខំ និងតម្រូវឱ្យបង្កការឈឺចាប់នោះទៅលើមនុស្ស [ម្នាក់ទៀត] [ដោយសារខ្លាចស្លាប់]"។ ជាក់ស្ដែង ម្ចាស់បណ្ដឹងសាទុក្ខស្ដីបន្ទោសដល់អង្គជំនុំជម្រះថាបានច្រានចោលសក្ខីកម្មនេះ ដោយមិនបានពន្យល់ថាហេតុអ្វីបានជាសក្ខីកម្មនេះគ្មានការចង្អុលបង្ហាញច្បាស់លាស់ ពាក់ព័ន្ធនឹងភាពធ្ងន់ធ្ងរនៃការឈឺចាប់ដែលបង្កឡើងដោយឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[56]។

៥៧. ក៏ប៉ុន្ដែ ដូចម្ចាស់បណ្ដឹងសាទុក្ខបង្ខំចិត្តទទួលស្គាល់អ៊ីចឹង[57] សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះត្រូវបានអង្គជំនុំជម្រះពិនិត្យយ៉ាងយកចិត្តទុកដាក់ និងប្រើប្រាស់ (ដោយមិនត្រឹមត្រូវ បើតាមមេធាវីការពារក្ដី) ជាច្រើនដង ក្នុងសាលក្រមលាយលក្ខណ៍អក្សរ វគ្គការរៀបអាពាហ៍ពិពាហ៍ ជាពិសេស ក្នុងផ្នែក ១៤.៣.១២.១ ក្រោមចំណងជើងថា *ផលប៉ះពាល់នៃ "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"*[58]។ សូមបញ្ជាក់ថា អែម អឿន មកបង្ហាញខ្លួនតែក្នុងក្របខ័ណ្ឌសំណុំរឿង ០០២/០១

[56] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩។

[57] សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩ "ភ័ស្តុតាងរបស់ អែម អឿន ត្រូវបានផ្អែក នៅក្នុងការវិភាគរបស់អង្គជំនុំជម្រះអំពីការព្រមព្រៀងសម្រាប់អាពាហ៍ពិពាហ៍ដោយបង្ខំ និងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ"។

[58] អង្គជំនុំជម្រះបានដកស្រង់ នៅកថាខណ្ឌ ៣៥៣៧ កថាខណ្ឌ ៣៦២១ និងជាពិសេស កថាខណ្ឌ ៣៦៧៩ កំណត់សម្គាល់ជើងទំព័រលេខ ១២២៧៤៖ "[...] ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ (អែម អឿន) ឯកសារ E1/113.1 ទំព័រ ៩០-៩១ "ក្នុងនាមខ្ញុំជាយុវជនម្នាក់ស្ថិតនៅក្នុងសង្គម អ្នកណាក៏ដូចអ្នកណា ស្រឡាញ់ណាស់អំពើមានសិទ្ធិសេរីភាពក្នុងការរើសគូស្រករ។ ប៉ុន្ដែនៅក្នុងឱកាសដែលខ្ញុំមិនចង់បាន បែរជាទៅបាន អាហ្នឹងខ្ញុំមិនពេញចិត្តទេ តែគេចមិនបាន។ [...] ទាំងនារីជាភរិយាខ្ញុំ ទាំងខ្ញុំដេក ពេលចូលដំណេកដេកជាមួយគ្នា បង្វែរទឹកភ្នែកដាក់គ្នា តើសមរម្យនឹងយកដែរឬទេ?"។

ដែលអង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍មិនត្រូវបានសន្មតថា យកមកពិនិត្យនោះទេ។ សំណួរអំពីការរៀបការរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចោទសួរដោយមេធាវីរបស់គាត់។ ម្យ៉ាងទៀត លោកប្រធានបានធ្វើអន្តរាគមន៍ពីរដង ដើម្បីរម្លឹកថា ប្រធានបទនេះស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តីសំណុំរឿង ០០២/០១[59]។ ដូច្នេះ មេធាវីការពារក្តីមិនអាចសួរដេញដោលលើប្រធានបទនេះបានទេ ហើយសក្ខីកម្មផ្នែកនេះមិនអាចត្រូវបានចាត់ទុកជាកម្មវត្ថុនៃកិច្ចពិភាក្សាដេញដោលចំពោះមុខទេ។ ដូចបានបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តី សក្ខីកម្មផ្នែកនេះរបស់ អែម អឿន មានតម្លៃជាភស្តុតាងតិចតួចបំផុត ដូចគ្នានឹងចម្លើយជាលាយលក្ខណ៍អក្សរ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ដែរ[60]។ ហេតុនេះ ចំណាត់ការបែបនេះរបស់អង្គជំនុំជម្រះគឺជារឿងត្រឹមត្រូវ។

៥៨. ប៉ុន្តែ ចំណុចសំខាន់នៅត្រង់ថា ជាទូទៅ សក្ខីកម្មរបស់ អែម អឿន ខ្វះភាពអាចជឿទុកចិត្តបាន។ ជាក់ស្តែង សហព្រះរាជអាជ្ញាបានសម្ងំស្ងៀមចំពោះភាពមិនសមទំនងជាច្រើន និងភាពផ្ទុយគ្នាមិនឈប់ឈរសព្វសារពើ ក្នុងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ល្មមគ្រប់គ្រាន់នឹងឱ្យតុលាការកំពូលលើកឡើង ក្នុងសាលដីកាសំណុំរឿង ០០២/០១[61]។ ឧទាហរណ៍ អែម អឿន បានអះអាងថា ខ្លួនគាត់បានកំណត់យកថ្ងៃទី១៧ ខែមេសា ជាថ្ងៃរៀបការ "ដោយបង្ខំ" របស់គាត់៖ "ដោយខ្ញុំនឹកឃើញថា នៅពេលនោះអ្នកដែលមានកម្មវិធីគាំទ្រ ស្រឡាញ់រាប់អានខ្ញុំជាបង ជាប្អូនខ្ញុំនោះ អ្នកមុខអ្នកការក្នុងតំបន់ទាំងអស់ទៅធ្វើពិធីការខ្ញុំ។ ដោយអ្នកទាំងអស់នុំងហាក់ដូចជាយល់គំនិតមួយថា បើសិនមិនអប់ -- បើមិនយកគំនិតហ្នឹងទៅការវាទេ ប្រហែលអាហ្នឹងវាមានទឹកចិត្តផ្សេង ព្រោះអស់ លោកដឹង។ ដឹងថា ខ្ញុំនឹងមិនចូលចិត្តស្តាប់អ្នកណាទាំងអស់។"[62]។

---

[59] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/113.1** ចន្លោះម៉ោង [16.05.36] ដល់ម៉ោង [16.06.56] អន្តរាគមន៍របស់លោកប្រធានចំពោះការតាំងសំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការរៀបការ។

[60] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ កែប្រែនៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧ ឯកសារ **E457/6/4/1** កថាខណ្ឌ ៥៥២-៥៥៣ ។

[61] សាលដីកាលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** កថាខណ្ឌ ៣៤៧។ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១៖ ប្រតិចារឹក ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣ ឯកសារ **E1/235.1** ចាប់ពីម៉ោង [13.59.09]។

[62] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/113.1** ក្រោយម៉ោង [16.03.12]។ ក្នុងចំណោមភាពផ្ទុយគ្នាផ្សេងទៀតរបស់ អែម អឿន នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គាត់និយាយថាគាត់បន្សល់មរស់ជាមួយ

៥៩. ម្យ៉ាងទៀត ពិតមែនតែ អែម អឿន បានលើកឡើងអំពីការឈឺចាប់ដោយសារការរៀបការដោយបង្ខំ ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម[63] ប៉ុន្តែគាត់មិនបាននិយាយអំពីការឈឺចាប់ជាក់លាក់បណ្តាលមកពីការរួមភេទជាមួយប្រពន្ធគាត់ទេ ទាំងក្នុងសេចក្តីថ្លែងចុងក្រោយមុនពេលបញ្ចប់សវនាការ[64] ទាំងក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[65]។ ជាពិសេស មេធាវីការពារក្តីគ្មានលទ្ធភាពសួរដេញដោលគាត់អំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ ដូច្នេះ ម្ចាស់បណ្តឹងសាទុក្ខមិនអាចបន្ទោសអង្គជំនុំជម្រះថាមិនបានប្រើសក្ខីកម្មរបស់ អែម អឿន អំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះឡើយ។

**១.២.២. អ្នកជំនាញ Kasumi NAKAGAWA**

៦០. ចំពោះអ្នកជំនាញ Kasumi NAKAGAWA ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងនូវការសន្និដ្ឋានផ្ទាល់ខ្លួនរបស់គាត់ ស្តីពីផលប៉ះពាល់នៃការរួមភេទដោយបង្ខំទៅលើបុរស[66]។ យោបល់របស់អ្នកជំនាញត្រូវបានអង្គជំនុំជម្រះទទួលយកជាចំហ ក្នុងការរកឃើញរបស់ខ្លួន នៅផ្នែក ១៤.៣.១២.២ *ផលប៉ះពាល់នៃការរួមដំណេកដោយបង្ខំទៅលើជនរងគ្រោះ* ដោយគ្មានភស្តុតាងច្បាស់លាស់គាំទ្រដល់យោបល់នេះ[67]។

---

ប្រពន្ធដែលបានរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ គាត់ហាក់ដូចជាបានលែងលះ នៅឆ្នាំ២០០២ និងបានរៀបការជាថ្មី បើតាមចម្លើយរបស់គាត់ក្នុងសវនាការ៖ ប្រតិចារិក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/116.1** ក្រោយម៉ោង [14.48.04] ក្រោយម៉ោង [14.51.11] និងមុនម៉ោង [14.55.41]។

[63] អែម អឿន៖ ប្រតិចារិក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/113.1** ក្រោយម៉ោង [15.58.36] ។

[64] អែម អឿន៖ ប្រតិចារិក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/117.1** ក្រោយម៉ោង [10.17.16]។

[65] ទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់ អែម អឿន ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ ឯកសារ **E3/1729** ERN 00573969-00573970។

[66] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០-៣១។

[67] កថាខណ្ឌ ៣៦៨៤ នៃសាលក្រមលាយលក្ខណ៍អក្សរ យោងផ្ទាល់មុខលើយោបល់របស់អ្នកជំនាញ Kasumi NAKAGAWA ដោយគ្មានឯកសារគាំទ្រផ្សេងទៀត។

៦១. នៅពេលសួរអំពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទៅលើបុរស អ្នកជំនាញបានអះអាងថា៖ "ពួកគេមិនបានសម្តែងពីអារម្មណ៍ចំពោះការរៀបការដោយបង្ខំ ហើយគេទទួលថាធ្វើម៉េចបើវាអ៊ីចឹងទៅហើយ ហើយពួកបុរសនោះ គាត់មិនមានវិប្បដិសារីអីធ្ងន់ធ្ងរខ្លាំងទេ"[68]។ ជាពិសេស គាត់បានបញ្ជាក់ថា គាត់បានសួរបុរសតិចតួចបំផុតអំពីប្រធានបទនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវរបស់គាត់[69]។

៦២. ក្នុងលក្ខខណ្ឌបែបនេះ ពាក់ព័ន្ធនឹងអារម្មណ៍របស់បុរសក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ មតិរបស់អ្នកជំនាញមានលក្ខណៈជាយោបល់ផ្ទាល់ខ្លួន ច្រើនជាងការសន្និដ្ឋានដែលបានមកពីការស្រាវជ្រាវស៊ីជម្រៅ។ មតិនេះមិនគ្រប់គ្រាន់ឱ្យអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានលើភាពធ្ងន់ធ្ងរដែលតម្រូវឱ្យមាន ដើម្បីកំណត់ឧក្រិដ្ឋកម្មថាជាអំពើអមនុស្សធម៌ផ្សេងទៀត និងមិនមែនជាភ័ស្តុតាងផ្ទាល់អំពីការឈឺចាប់របស់បុរស ដែលជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ នោះឡើយ។

## ២. នត្ថិភាពនៃភាពពាក់ព័ន្ធ និងតម្លៃនៃភ័ស្តុតាងប្រយោល

៦៣. ដើម្បីព្យាយាមប៉ះប៉ូវអវត្តមាននៃភ័ស្តុតាងផ្ទាល់ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងអំពីភ័ស្តុតាងដែលត្រូវបានប្រើប្រាស់ ដើម្បីធ្វើសេចក្តីសន្និដ្ឋានអំពីការឈឺចាប់របស់ស្ត្រី (២.១) ក៏ដូចជាសេចក្តីថ្លែងការណ៍ និងរបាយការណ៍សិក្សា នៅក្នុងសំណុំរឿង (២.២)។ ភ័ស្តុតាងទាំងនេះមិនគ្រប់គ្រាន់ឱ្យបង្ហាញអំពីការឈឺចាប់របស់បុរសនោះទេ។

### ២.១. ភ័ស្តុតាងដែលត្រូវបានប្រើប្រាស់ ដើម្បីសន្និដ្ឋានថាស្ត្រីបានទទួលរងការឈឺចាប់ធ្ងន់ធ្ងរ

---

[68] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** មុនម៉ោង [14.37.03]។

[69] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** ក្រោយម៉ោង [15.33.50] "ខ្ញុំមិនមានរឿងរ៉ាវច្រើនមកពីបុរសៗទេ ដែលរៀបការនៅក្នុងសម័យខ្មែរក្រហម ជាពិសេសអំពីរបៀបដែលអារម្មណ៍របស់គេ ដែលថាឪពុកម្តាយមិនបានចូលរួម"។ គាត់បានជ្រើសរើសផ្តោតការស្រាវជ្រាវលើស្ត្រី៖ "អ៊ីចឹងហើយខ្ញុំគិតថា ខ្ញុំនេះអាចចែករំលែកចំណេះដឹង ដោយប្រមូលព័ត៌មាន និងភ័ស្តុតាងនានា ពាក់ព័ន្ធទៅនឹងថាតើហេតុអ្វីក៏រឿងនេះកើតឡើង ជាពិសេស អំពីទស្សនៈរបស់ស្ត្រីនេះតែម្តង ដោយសារថាយើងអត់មានភ័ស្តុតាងណាប្រមូលចងក្រងជាប្រវត្តិសាស្ត្រទេ" ឯកសារ **E1/472.1** មុនម៉ោង [09.56.34]។

៦៤. ម្ចាស់បណ្ដឹងសាទុក្ខស្ដីបន្ទោសអង្គជំនុំជម្រះថាមិនបានផ្ដល់ទម្ងន់ដល់ភ័ស្ដុតាង ដែលបង្ហាញជូនក្នុងផ្នែក ក្រោមចំណងជើងថា "បរិយាកាសបង្ខិតបង្ខំ" និង "ការរួមដំណេកដោយបង្ខំរវាងប្ដីប្រពន្ធ" នៅពេលអង្គជំនុំជម្រះធ្វើការវិភាគលើការឈឺចាប់ដែលបុរសបានទទួលរង ប៉ុន្ដែ អង្គជំនុំជម្រះបែរជាផ្ដល់ទម្ងន់ដល់ភ័ស្ដុតាងបែបនេះចំពោះស្ត្រី[70]។ ផ្ទុយទៅវិញ ការពិនិត្យហ្មត់ចត់លើភ័ស្ដុតាងដែលអង្គជំនុំជម្រះបានទទួលយក នៅក្នុងផ្នែកទាំងពីរនេះ ដោយឧបមាថាជាការឈឺចាប់របស់បុរស ក៏មិនអាចឱ្យសន្និដ្ឋានថាមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ឱ្យបង្ហាញអំពីឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត បានឡើយ។

៦៥. សាក្សី ប្រាក់ យុត ជាលេខាស្រុកកំពង់សៀម បានអះអាងថា បន្ទាប់ពីរៀបការរួច "បើយើងគិតទៅ វាត្រូវតែរួមដំណេក បើមិនរួមដំណេក យើងថារៀបការយ៉ាងម៉េច"[71]។ ប៉ុន្ដែ សាក្សីដដែលនេះបានពន្យល់ថា ការរៀបការមិនអាចចេះតែរៀបចំដោយគ្មានការយល់ព្រមពីសាមីខ្លួនបានទេ បើមិនអ៊ីចឹងទេ "ហ្នឹងវាខុសដែរ"[72]។ គាត់បានបញ្ជាក់ផងដែរថា៖ "ចំពោះគូស្រករមិនរួមដំណេក ខ្ញុំអត់មានវិធានការអីដែលធ្វើឱ្យគូស្រករទាំងពីរនាក់នោះបាត់បង់អីទេ មានការអប់រំនៅក្នុងស្រុក ដើម្បីឱ្យគូស្រករទាំងពីរនោះចេះយល់ចិត្ត យល់គំនិតគ្នា ព្រោះយើងការរួចហើយ តែថាឱ្យយកគូស្រករទាំងពីរនាក់នេះ ខ្ញុំជាចៅហ្វាយស្រុក ដែលគាត់មិនបានរួមដំណេក ហើយយកគាត់ធ្វើបាបធ្វើទោសគឺអត់មាន"[73] (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ទោះជាជឿ ឬមិនជឿលើសក្ខីកម្មនេះក៏ដោយ

[70] កថាខណ្ឌ ៣៣ នៃសារណាបណ្ដឹងសាទុក្ខ៖ ផ្នែកទាំងពីរនេះបង្ហាញថា កម្មាភិបាលបានតាមដានថាតើមានការរួមដំណេកដែរឬទេ, ប្ដីប្រពន្ធត្រូវប្រឈមជីវិត ប្រសិនបើពួកគេប្រឆាំងនឹងអង្គការ, ផលវិបាកអវិជ្ជមានចំពោះប្ដីប្រពន្ធដែលប្រកែកមិនព្រមរួមដំណេក និង "បុគ្គលទាំងនោះទទួលរងការភ័យខ្លាច ដូច្នេះហើយ ទាំងបុរស និងនារីទាំងនោះសុទ្ធតែមិនយល់ព្រមដោយពិតប្រាកដឡើយ"។

[71] សាក្សីដែលត្រូវបានលើកឡើងនៅកថាខណ្ឌ ៣៦៤៥ (បរិយាកាសបង្ខិតបង្ខំ) និងកថាខណ្ឌ ៣៦៥៦ (ការរួមដំណេកដោយបង្ខំរវាងប្ដីប្រពន្ធ)។

[72] ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/378.1** មុនម៉ោង [11.27.14] "ខ្ញុំអត់មានរៀបរយឱ្យទេ ព្រោះកាលណារៀបរយឱ្យ កាលណាគេអត់ស្រឡាញ់គ្នា យើងទៅបង្ខិតបង្ខំ ហ្នឹងវាខុសដែរ។ ខ្ញុំមើលឯកសារខ្លះដែរ ខ្ញុំមិនមែនចេះតែធ្វើទេ" [...]។ សូមមើលផងដែរ ឯកសារ **E1/378.1 សម្ងាត់** មុនម៉ោង [11.27.14] "តែទាល់តែស្ម័គ្រចិត្តរៀងខ្លួន បានខ្ញុំហ៊ានការ"។

[73] ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/378.1 សម្ងាត់** ក្រោយម៉ោង [13.47.27]។ គួរកត់សម្គាល់

ក៏គេមិនអាចទាញការសន្និដ្ឋានអំពីការទទួលរងការឈឺចាប់ ដោយសារតែអំពើហិង្សាផ្លូវភេទចំពោះអ្នកណាម្នាក់បានឡើយ។

៦៦. ដូចអ្នកជំនាញ Peg LEVINE បានអះអាងអ៊ីចឹង "បើយើងនិយាយអំពីនៅលោកខាងលិច និយាយអំពីយប់ គេហៅថារាត្រីទឹកឃ្មុំនោះ គឺគេត្រូវគោរពគ្រប់គ្នា"[74]។ ចំណុចនេះផ្ទុះបញ្ចាំងអំពីការយល់ឃើញជាទូទៅអំពីការរៀបអាពាហ៍ពិពាហ៍ថា ការរួមដំណេករវាងប្ដីប្រពន្ធ គឺជាអ្វីដែលគេរំពឹងចង់បានពីការរៀបការ រួមទាំងនៅក្នុងប្រពៃណីខ្មែរមុនសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ[75]។

៦៧. ដើមបណ្ដឹងរដ្ឋប្បវេណី ណុប ធីម ដែលបានរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានអះអាងថា៖ "ការហើយក៏ខ្ញុំអត់មានអីទេ ចេះតែទ្រាំយកគ្នាទៅ ធ្វើម៉េចទេអង្គការការឱ្យហើយ គេជំនាន់គេហៅអង្គការហើយចុះ។ អង្គការការឱ្យចេះតែទ្រាំយកទៅ បានគ្នាជាកូន បានជាចៅហើយ"[76]។ គាត់បានបន្ថែមទៀតថា៖ "គឺចំពោះខ្លួនខ្ញុំ អត់មានបង្ខំ ខាងនោះក៏មិនបង្ខំដែរ សំខាន់គឺចិត្ត។ ដូចខ្ញុំថា ថាគោរពវិន័យចាត់តាំង គឺយើងនៅក្រោមគេដឹកនាំ។ ចំពោះខ្លួនខ្ញុំអ៊ីចឹង អត់មាននិយាយថាណាៗ និយាយថាណា អត់ទេ គឺចំពោះប្ដីប្រពន្ធខ្ញុំអត់សោះ។ អត់មានអ្នកណាបង្ខំណា អត់ទេ"[77]។

---

ថា សក្ខីកម្មនេះត្រូវបានផ្ដល់ជូន ជាការឆ្លើយតបទៅនឹងការដកស្រង់មិនពេញលេញរបស់អង្គជំនុំជម្រះ នៅកថាខណ្ឌ ៣៦៥៦ ក្នុងផ្នែក ១៤.៣.៨.២ *ការរួមដំណេកដោយបង្ខំរវាងប្ដីប្រពន្ធ* ដែលថា ប្ដីប្រពន្ធទើបរៀបការថ្មោងថ្មីត្រូវគេអប់រំនៅថ្នាក់ស្រុក ក្នុងករណីមិនព្រមរួមដំណេក។

[74] Peg LEVINE៖ ប្រតិចារឹក ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/480.1** ក្រោយម៉ោង [15.48.30]។ សូមមើល ឯកសារ **E1/483.1** ក្រោយម៉ោង [11.00.42] "ឆ៖ នេះគឺជាការសម្ភាសន៍លម្អិត [...]។ ប៉ុន្តែ មានអ្នកខ្លះទៀតគាត់គិតថាតែរៀបការហើយ គឺត្រូវតែផ្សំដំណេកបែបនេះហើយ ហើយបន្ទាប់ពីផ្សំដំណេកហើយ ត្រូវមានកូនមានចៅអី វាជារឿងធម្មតា។ ប៉ុន្តែ យ៉ាងណាក៏ដោយ មនុស្សភាគច្រើនគាត់និយាយថា ពួកគាត់អត់កម្លាំង [...]"។

[75] កថាខណ្ឌ ៣៦៤៥ នៃសាលក្រមលាយលក្ខណ៍អក្សរ។

[76] ណុប ធីម៖ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ក្រោយម៉ោង [10.47.19]។ "កាលហ្នឹងណា គេយកការមានប្រវត្តិរូបល្អ គូហ្នឹង គូជាមួយតាខ្ញុំ ហើយខ្ញុំមានប្រវត្តិរូបល្អ គេយកដាក់ជាមួយគ្នាទៅ ហើយត្រូវគ្នាទៅ។ ប៉ុន្តែទឹកចិត្តខ្ញុំនោះវាទាំងសងខាង ទឹកចិត្តវាមិនពេញចិត្តទេ ប៉ុនដល់បានគ្នាទៅ ចេះតែសាមគ្គីគ្នាទៅ ធ្វើម៉េចគេការឲ្យ" ឯកសារ **E1/469.1** មុនម៉ោង [10.43.35]។

[77] ណុប ធីម៖ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** មុនម៉ោង [14.20.13]។ "គឺខ្លាចឈ្លបតាម គឺកន្លែងហ្នឹង វាមានកងឈ្លប មានកូនប្រជាជន ព្រោះអីចេះតែខ្លាចទៅ ខ្លាចក្រែងលោគេលបស្ដាប់ទៅ ចេះតែណែនាំគ្នាឲ្យបានល្អទៅ" ឯកសារ **E1/469.1** មុនម៉ោង [14.15.24]។ គាត់មិនធ្លាប់ឮសេចក្ដីណែនាំឲ្យតាមដាន ឬទណ្ឌកម្ម ឬពិន័យ ក្នុងករណីមិនរួម

ប្ដីគាត់ឈ្មោះ ព្រាប កប ដែលត្រូវបានស្ដាប់ចម្លើយនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ មិនបាននិយាយអំពីការឈឺចាប់បណ្ដាលមកពីទំនាក់ទំនងប្ដីប្រពន្ធរបស់គាត់នោះឡើយ[78]។

៦៨. សាក្សី អ៊ុន យឿង ដែលនៅតែរួមរស់ជាមួយប្ដីគាត់ឈ្មោះ ចាន់ គា ត្រូវបាន "កម្មាភិបាលប្រាប់ឱ្យរួមដំណេក ហើយប្រសិនបើគាត់បដិសេធ គាត់ និងប្ដីរបស់គាត់នឹងត្រូវគេយកទៅមន្ទីរឃុំ ដើម្បីធ្វើយ៉ាងណាឱ្យពួកគេរួមដំណេក"[79]។ ប៉ុន្ដែ ក្នុងករណីជាក់លាក់នេះ នេះគឺជាការរៀបការស្ម័គ្រចិត្ត[80] ដែលទាំងសាក្សី និងប្ដីគាត់ មិនបានលើកឡើងអំពីការឈឺចាប់ នៅក្នុងទំនាក់ទំនងស្និទ្ធស្នាលរបស់ពួកគាត់នោះទេ។ ម្យ៉ាងវិញទៀត ចាន់ គា បានអះអាងក្នុងកិច្ចសម្ភាសន៍មួយថា៖ "ទាល់តែយើងស្ម័គ្រចិត្តដែរបានគេការឱ្យ"[81]។

៦៩. នៅកថាខណ្ឌ ៣៦៤៥ នៃសាលក្រមលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះបានយកសក្ខីកម្មរបស់ ប្រាក់ ឌឿន និង ជាំង ស្រីមុំ មកធ្វើការសន្និដ្ឋានថា កម្មាភិបាលមូលដ្ឋានបានណែនាំគូស្វាមីភរិយាឱ្យរួមដំណេក។ ប្រាក់ ឌឿន បាននិយាយអំពីការរៀបការដែលត្រូវបានរៀបចំឡើងតាមការស្នើ ឬផ្សំផ្គុំដោយគ្មានសួរនាំ[82]។ គាត់បានអះអាងថា គាត់បានស្ដាប់ឮថា ប្ដីប្រពន្ធទើបរៀបការថ្មី ដែលមិនចុះសម្រុងនឹងគ្នា មិនត្រូវបានគេដាក់ទណ្ឌកម្មទេ គឺគេអប់រំ។ គេណែនាំឱ្យរួមដំណេកដេកនៅជាមួយគ្នា និងកុំឱ្យបន្ទោសអង្គការ[83]។ ប៉ុន្ដែវាគ្រាន់តែជាការឮតៗគ្នាប៉ុណ្ណោះ ពីព្រោះ ប្រាក់ ឌឿន

---

ដំណេកទេ ឯកសារ **E1/469.1** ក្រោយម៉ោង [14.18.30] និងមុនម៉ោង [13.49.09]។

[78] កំណត់ហេតុស្ដាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ **E3/9818** ស./ឆ.៧៦-៧៧៖ "នៅសម័យនោះ មានគេប្រាប់លោកថា លោកត្រូវតែរួមដំណេកជាមួយប្រពន្ធរបស់លោក ដើម្បីឱ្យមានកូនដែរឬទេ?។ ឆ.៧៦៖ អត់ទេ។ ស៖ តើគេប្រាប់ ឬមានការណែនាំពីថ្នាក់លើថា ការរស់នៅជាប្ដីប្រពន្ធហ្នឹង របបនោះមានចង់បានអ្វីពីលោកទេ? ឆ.៧៧៖ អត់មានទេ"។ ស./ឆ.៥៣៖ ពួកគាត់មិនត្រូវបានគេតាមដានអំពីការរួមដំណេកទេ។

[79] កថាខណ្ឌ ៣៦៤៥ នៃសាលក្រមលាយលក្ខណ៍អក្សរ។

[80] អ៊ុន យឿង៖ ប្រតិចារឹក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/387.1** ក្រោយម៉ោង [15.39.34] និងមុនម៉ោង [14.18.13]។

[81] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ចាន់ គា ឯកសារ **E3/7525** ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ជាពិសេស ERN 00089612។

[82] ប្រាក់ ឌឿន៖ ប្រតិចារឹក ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/361.1** ក្រោយម៉ោង [15.54.43]។

[83] ប្រាក់ ឌឿន៖ ប្រតិចារឹក ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/361.1** ក្រោយម៉ោង [15.58.55]។ "កម្មាភិបាលហ្នឹងផ្នែកខាងទទួលខុសត្រូវរៀបចំមេគ្រួសារ គេឱ្យយោបល់ដែរ សូមមិត្តទាំងអស់គ្នា ណ៎ះ! មិត្ត ដែលខ្ញុំទទួលប្រគល់ភារកិច្ចអង្គការចាត់

មិនបានរៀបការទេ ក្នុងរបបនោះ[84]។ ចំណែកឯ ជាំង ស្រីមុំ គាត់បានបញ្ជាក់ថា គាត់គ្មានជម្រើសអ្វីក្រៅពីរៀបការទេ ដោយសារខ្លាចគេសងសឹក បន្ទាប់មក គាត់បាននិយាយអំពីការរីកលូតលាស់នៃមនោសញ្ចេតនារៀងៗខ្លួន[85]។ ជាក់ស្តែង តបទៅនឹងសំណួរសួរថា ហេតុអ្វីបានជាគាត់ចាត់ទុកការរួមរស់ជាមួយគ្នាជាចំណងអាពាហ៍ពិពាហ៍ដ៏មានសុភមង្គល គាត់បានឆ្លើយថា ទោះបីជាយ៉ាងណាក៏ដោយ ប្តីគាត់មិនបាន "បង្ខំ" គាត់ទេ[86] ហើយគាត់បានបន្ថែមទៀតថា ថ្វីត្បិតតែគាត់មានអារម្មណ៍ខកចិត្តពីដំបូង ដោយសារប្តីគាត់ស្រឡាញ់នារីផ្សេង ប៉ុន្តែ ក្រោយមក ប្តីគាត់ប្រាប់ថាចាត់ទុកគាត់ជា "គូព្រេង"[87]។ ប្តីប្រពន្ធគូនេះរួមរស់ជាមួយគ្នារហូត ហើយក្នុងសក្ខីកម្មនេះ គ្មានកន្លែងណាមួយអាចឱ្យសន្និដ្ឋានបានថា ប្តី ឬប្រពន្ធនេះបានទទួលរងហិង្សាផ្លូវភេទឡើយ។

---

តាំងមកឱ្យរៀបមង្គលការ តើគូស្វាមីភរិយាហ្នឹងពេញចិត្តនឹងអង្គការ ឬក៏អត់? គេបានថាអ៊ីចឹង។ បើពេញចិត្តហើយ អង្គការចាត់តាំងទៅកន្លែងណា ត្រូវគោរពភារកិច្ច ហើយអ្នកទាំងអស់គ្នាជាគូស្វាមីភរិយាបានទទួលបញ្ហាដែលគេចាត់តាំងដាក់ទិសហ្នឹងឱ្យគ្រប់ៗគ្នា។ ខ្ញុំបាទបានឮតែប៉ុណ្ណឹង" ឯកសារ **E1/361.1** ក្រោយម៉ោង [15.58.55]។

[84] ប្រាក់ ខឿន៖ ប្រតិចារឹក ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/361.1** ក្រោយម៉ោង [15.58.55]។

[85] ជាំង ស្រីមុំ៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** ក្រោយម៉ោង [10.43.16] "ស៖ តើចិត្តពិតប្រាកដរបស់លោកស្រីនៅពេលនោះ លោកស្រីចង់ធ្វើដូច្នេះ ឬក៏លោកស្រីគិតថាគ្មានជម្រើសអ្វីផ្សេងត្រូវធ្វើ? ឆ៖ ចាស ខ្ញុំគិតថា គ្មានជម្រើសអ្វីផ្សេងក្រៅពីប្តីប្រពន្ធ។ បើកាលណាបើខ្ញុំមិនយកគ្នា គឺខ្ញុំខ្វះសេចក្តីសុខ ខ្ញុំនឹងបាត់បង់ជីវិត។ អ៊ីចឹង ខ្ញុំត្រូវតែដាក់ចិត្ត ខ្ញុំពិចារណាក្នុងចិត្ត ដេកគិតថា ខ្ញុំចៀសមិនផុតពីប្តីប្រពន្ធ អ៊ីចឹង ខ្ញុំត្រូវតែដាក់ចិត្តនៅពេលហ្នឹង។ ដាក់ចិត្ត ហើយក្នុងចិត្តហ្នឹងចេះតែមានកូនចិត្តមួយ ចេះតែបន់ស្រន់ អ៊ីចឹង ថាបើពិតជាគូព្រេងរបស់ខ្ញុំឱ្យចិត្តខ្ញុំចេះតែមានការទោរទន់អ៊ីចឹង ហ្នឹងខ្ញុំនិយាយចិត្តខ្ញុំជាការពិតតែម្តង។ ខ្ញុំថ្ងៃណាក៏ខ្ញុំបន់ស្រន់ព្រះដែរ បើថាពិតមែនជាបុរសហ្នឹងជាគូព្រេងរបស់ខ្ញុំ សូមឱ្យចិត្តខ្ញុំទោរទន់មានចិត្តអាណិតគេ។ ពេលនោះ ហាក់បីដូចជាគូព្រេងរបស់ខ្ញុំ រហូតមកដល់សព្វថ្ងៃ ចេះចិត្តខ្ញុំដូចថា វាចេះតែដាក់ចិត្តម្តងបន្តិចៗ មានការស្រឡាញ់ប្តី"។

[86] ជាំង ស្រីមុំ៖ ប្រតិចារឹក ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/255.1** ក្រោយម៉ោង [09.27.21] "ចំពោះប្តីរបស់ខ្ញុំក៏អត់មានបង្ខំដែរ ប៉ុន្តែ គឺសម្រេចចិត្តដាក់ខ្លួន ដាក់ចិត្ត បើកាលនោះ គឺអង្គការគឺសម្រេចតែរៀបចំទៅលើអ្នកណាមួយហើយ គឺយើងអត់មានប្រឆាំងជាមួយបក្សបានទេ [...] ការស្រឡាញ់ មិនស្រឡាញ់គ្នា ក៏ត្រូវតែស្រឡាញ់ដែរពេលហ្នឹង"។

[87] ជាំង ស្រីមុំ៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** ក្រោយម៉ោង [10.48.26] "ប៉ុន្តែចំពោះខ្ញុំ ចេះតែយល់ឃើញថាគាត់មិនស្រឡាញ់ខ្ញុំ ព្រោះអីគាត់មាននារីផ្សេងអ៊ីចឹង ខ្ញុំក៏មានចិត្តមួយចេះតែពិចារណាថា ប្តីក៏មិនសូវស្រឡាញ់ខ្ញុំ ប៉ុន្តែ តាមការពិត ខ្ញុំមើលតែខាងក្រៅទេ តែចិត្តគេៗអត់អីទេ ពិតមែនគេថាគេនារីផ្សេងគេមិនត្រូវជាគូព្រេងរបស់គេ គេចាត់ទុកថាខ្ញុំហ្នឹងជាគូព្រេង ម្ល៉ោះហើយពេលហ្នឹង គេដាក់ចិត្តហើយ"។

៧០. សយ ណាវឿន ជាដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ដល់សក្ខីកម្មអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មនៃវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ បានបញ្ជាក់ថា គាត់រស់នៅជាមួយប្ដីបានបីថ្ងៃ ក្រោយពីរៀបការរួច ហើយក្រោយមក ពួកគាត់បានជួបគ្នា ប្រហែលមួយសប្ដាហ៍ម្ដង នៅផ្ទះម្ដាយរបស់គាត់[88]។ ថ្វីត្បិតតែគាត់បានអះអាងពីដំបូងថា គាត់មានការភ័យខ្លាច និងអៀនខ្មាសក្នុងនាមជាស្ត្រីខ្មែរមួយរូប ប៉ុន្តែគាត់ "សុខចិត្តថានៅស្ងៀមដើម្បីឱ្យប្តីបម្រើទៅតាមចំណង់ចំណូលចិត្តរបស់គាត់រួមភេទ"[89] ហើយបន្ទាប់មក ពេលជួបគ្នាលើកក្រោយៗទៀត គាត់បានឆ្លើយថា "ធ្វើម៉េចបើបានជាជ្រុលទៅបាត់ទៅហើយ មិនដឹងទៅប្រកែកថាម៉េច មិនដឹងធ្វើម៉េច ក៏ចេះតែតាមដំណើរធម្មជាតិរបស់ស្ត្រី និងបុរសទៅ"[90]។ ក្នុងសក្ខីកម្មនេះទៀត គ្មានកន្លែងណាមួយអាចឱ្យសន្និដ្ឋានថាមានហិង្សាផ្លូវភេទក្នុងកម្រិតធ្ងន់ធ្ងររហូតដល់ថ្នាក់ចាត់ទុកជាឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀតឡើយ។

៧១. នៅកថាខណ្ឌ ៣៦៤៦ នៃសាលក្រមលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះលើកឡើងថា ក្នុងករណីនៃដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន គឺប្ដីគាត់បង្ខំគាត់ឱ្យរួមភេទ។ ដោយសារតែគាត់រឹងទទឹង ប្ដីគាត់បានទៅប្ដឹងមេបញ្ជាការយោធា ដែលបានចាប់រំលោភគាត់ និងគំរាមសម្លាប់ បើគាត់ប្រាប់គេ[91]។ គាត់បានរួមភេទជាមួយប្ដីគាត់ មួយ ឬពីរក្រោយខែការរំលោភនេះ[92]។ ក្រៅពីបញ្ហាវិសាលភាពបណ្ដឹងលើអង្គហេតុ ដែលនឹងត្រូវលើកឡើងនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី

[88] សយ ណាវឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ក្រោយម៉ោង [10.51.06]។

[89] សយ ណាវឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ក្រោយម៉ោង [10.48.25] "ខ្លួនខ្ញុំជាស្ត្រីខ្មែរមួយរូប អ្វីៗក៏មិនសំខាន់ដល់ស្មើនឹងខ្លួនរបស់នាងខ្ញុំដែរ។ តែនាងខ្ញុំសុខចិត្តញាក់ព័រ ដូចកូនសត្វយ៉ាងណាក៏ដោយ ក៏នាងខ្ញុំសុខចិត្តថានៅស្ងៀម ដើម្បីឱ្យប្ដីបម្រើទៅតាមចំណង់ចំណូលចិត្តរបស់គាត់រួមភេទ ព្រោះគាត់បានប្ដេជ្ញាចិត្តនៅមុខអង្គការ"។

[90] សយ ណាវឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ក្រោយម៉ោង [11.10.23]។

[91] កថាខណ្ឌ ៣៦៤៦ និងកថាខណ្ឌ ៣៦៥៨ នៃសាលក្រមលាយលក្ខណ៍អក្សរ កត់សម្គាល់អំពីការរំលោភសេពសន្ថវៈ នៅក្រៅវិសាលភាពនៃការជំនុំជម្រះក្ដី។ អ៊ុំ យឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ក្រោយម៉ោង [09.10.01] "ចាស គេអត់មានបានប្រាប់នាងខ្ញុំទេ ចាស។ តែចូលទៅ ឃើញមានប្ដីអីនៅនុ៎ង គេចូលទៅនុ៎ងដែរ ចាស។ [...] ដំណើរនាងខ្ញុំរៀងខ្លាចដែរ ហើយខ្លាំងដែរ ប្រតាយគ្នាទៅ គេចេញទៅប្រាប់នឹងប្រធានគេវិញ ព្រោះប្រធានគេហ្នឹង ប្រធានយោធាផ្ទាល់ ចាស។ ស៖ ហេតុផលអ្វីបានជាអ្នកស្រីប្រតាយជាមួយនឹងស្វាមីអ្នកស្រី នៅយប់នោះ? ឆ៖ ខ្ញុំមិនពេញចិត្ត ហើយមនុស្សនោះចូលទៅគ្មានការល្លួងលោមសិន អាពេលទៅដល់ទឹងណាត់ទឹងណែងហ្នឹង។ របៀបដូចជាមនុស្សចង់ចាប់រំលោភបង្ខំហ្នឹង ចាស។ ស៖ អម្បាញ់មិញលោកស្រីថាមានការប្រតាយប្រតប់គ្នាមិនព្រមរួមដំណេក ហើយគាត់ ស្វាមីនោះចេញ។ គេចេញទៅណាដែរ លោកស្រី? ឆ៖ គេចេញមកប្រាប់ប្រធាន ចាស"។ សូមមើលផងដែរ ឯកសារ **E1/462.1** ក្រោយម៉ោង [13.41.13]។

[92] អ៊ុំ យឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ប្រហែលម៉ោង [13.31.33]។

គួរកត់សម្គាល់ថា គេអាចគិតស្រមៃឃើញយ៉ាងលំបាកដល់ការឈឺចាប់របស់ប្ដីរូបនេះ ដែលមានបំណងចង់រួមភេទដោយហិង្សា។

៧២. ម៉ម សឿន បានលើកឡើងអំពីការរៀបការពីរប្រភេទ គឺតាមការស្ម័គ្រចិត្ត និងដោយបង្ខំ[93]។ ប៉ុន្តែពេលសួរអំពីការតាមដានប្ដីប្រពន្ធទើបរៀបការថ្មោងថ្មី គាត់បានឆ្លើយថា “បាទ អាត្រង់រឿងនេះ ខ្ញុំមិនអាចជម្រាបបានទេ ព្រោះខ្ញុំមិនបានចូលជ្រៅក្នុងបញ្ហាអ្នកដែលរៀបការនៅពេលនោះ ខ្ញុំមិនអាចទៅជិតគេបាន”[94]។ ដូច្នេះ សក្ខីកម្មជារួម និងមិនច្បាស់លាស់របស់គាត់ អំពីការមិនព្រមរួមដំណេក ដែលអាចគំរាមកំហែងដល់ជីវិតប្ដីប្រពន្ធ មិនអាចយកមកធ្វើជាមូលដ្ឋាន ដើម្បីបង្ហាញអំពីកម្រិតធ្ងន់ធ្ងរនៃការឈឺចាប់របស់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ជាបុរស ឬស្ត្រី បានឡើយ។

៧៣. ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ មិនបានលើកឡើងពីការឈឺចាប់ជាយថាហេតុណាមួយរបស់ស្វាមីលោកស្រីឡើយ ដោយលោកស្រីគ្រាន់តែលើកឡើងពីអំពើហិង្សា និងការរំលោភសេពសន្ថវៈដែលលោកស្រីបានទទួលរង។ បើទោះបីជាលោកស្រីបាននិយាយថា កងឈ្លបម្នាក់បានប្រាប់ស្វាមីលោកស្រីថា “រៀបចាប់ដៃហើយគឺប្ដីប្រពន្ធហើយ ធ្វើអ្វីក៏ធ្វើទៅ”[95]។ ក៏ប៉ុន្តែ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មិនអាចចង្អុលបង្ហាញ ថាតើស្វាមីលោកស្រីត្រូវបានគេធ្វើបាប ឬកសាង បន្ទាប់ពីបរាជ័យក្នុងការរួមមេត្រី នៅរាត្រីផ្សំដំណេកដំបូង[96]។ ជាក់ស្ដែង លោកស្រីបានប្រាប់ថា លោកស្រីបានចាកចេញពីស្វាមី បន្ទាប់ពីត្រូវបានរំលោភសេពសន្ថវៈនៅរាត្រីទីបី និងលែងបានជួបស្វាមី

---

[93] ម៉ម សឿន៖ ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/325.1** ក្រោយម៉ោង [10.00.24]។ “ភាគីខាងនារីពេញចិត្តនឹងបុរសដូចជាត្រូវគ្នាទៅ បើនារីមិនពេញចិត្តនឹងបុរស វាពិបាក។ ដូច្នេះ ការរៀបការនេះឯងមួយបង្ខំ មួយមិនបង្ខំ” ឯកសារ **E1/325.1** មុនម៉ោង [10.03.19]។

[94] ម៉ម សឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/324.1** ក្រោយម៉ោង [15.55.46]។

[95] ប៉ែន សុចាន់៖ ប្រតិចារឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/483.1** ក្រោយម៉ោង [09.55.09]។

[96] គួរកត់សម្គាល់ថាដមបណ្ដឹងរដ្ឋប្បវេណីបានត្រឡប់ទៅសេចក្ដីថ្លែងអាងរបស់គាត់ពីលើកមុន ដែលថាស្វាមីគាត់ ប្រហែលជាត្រូវគេកោះហៅឲ្យចូលប្រជុំ នៅយប់ទីពីរបន្ទាប់ពីយប់ផ្សំដំណេក ហើយពេលត្រឡប់មកវិញ ប្រហែលជាព្យាយាមចាប់បង្ខំគាត់ឲ្យរួមដំណេក ហើយបានទះកំផ្លៀងគាត់ ពេលគាត់បដិសេធ៖ ប្រតិចារឹក ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** មុនម៉ោង [15.49.36] និងថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** នៅម៉ោង [11.42.14]។ ទម្រង់បែបបទព័ត៌មានស្ដីពីជនរងគ្រោះ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៩ ឯកសារ **E3/3779** ERN FR 00900951។

ចាប់តាំងពីគ្រានោះមក[97]។ ទោះជាយ៉ាងណាក្តី សក្ខីកម្មរបស់គាត់គ្រាន់តែលើកឡើងពីការឈឺចាប់ផ្ទាល់ខ្លួនគាត់តែប៉ុណ្ណោះ។

៧៤. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន មិនបានរៀបរាប់ពីការឈឺចាប់បណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ឡើយ ទាំងនៅក្នុងសក្ខីកម្មនៅចុងបញ្ចប់នៃសវនាការ ទាំងនៅក្នុងសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់[98]។ លោកស្រីពិតជាបានពិពណ៌នាពីភាពភ័យខ្លាចនៅរាត្រីផ្សំដំណេកដំបូង ក្នុងនាមជាយុវតីខ្មែរ តែលោកស្រីផ្តោតការពិពណ៌នាលើភាពស្លូតបូតរបស់ស្វាមីដែលសុខចិត្តរង់ចាំសិនមុននឹងរួមមេត្រី[99]។ សក្ខីកម្មរបស់គាត់នឹងមិនអាចយកមកប្រើប្រាស់ ដើម្បីសន្និដ្ឋានពីទំហំនៃការឈឺចាប់ដែលបណ្តាលមកពីអំពើហិង្សាផ្លូវភេទ នៅក្នុងបរិបទអាពាហ៍ពិពាហ៍របស់លោកស្រី ឬស្វាមីលោកស្រីឡើយ។

៧៥. នៅក្នុងកថាខណ្ឌ៣៦៤៦ និង៣៦៥៥ នៃសាលក្រមជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជា ឌៀប និង ផាន់ ហ៊ីម បានទទួលស្គាល់ថា ពួកគាត់បានរួមរ័កជាមួយស្វាមីរៀងៗខ្លួន។ ផាន់ ហ៊ីម បានរៀបការទៅតាមសំណើរបស់ស្វាមីគាត់[100]។ លោកស្រីបានអះអាងថាមានចិត្តអាណិត ក្រោយពេលស្វាមីទម្លាយអាថ៌កំបាំងពីក្រុមគ្រួសារ បន្ទាប់ពីរៀបការរួច និងបានសម្រេច

---

[97] ប្រតិចារឹក ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ចន្លោះពីម៉ោង [11.17.14] ដល់ម៉ោង [11.23.35]។

[98] ជុំ សាមឿន៖ ប្រតិចារឹក ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/321.1** ក្រោយម៉ោង [15.47.49] ។ ទម្រង់បែបបទព័ត៌មានស្តីពីជនរងគ្រោះ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០០៨ ឯកសារ **E3/6160**, ERN KH 00518245។

[99] ជុំ សាមឿន៖ ប្រតិចារឹក ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/321.1** ក្រោយម៉ោង [14.29.44] "ស. [...] តើលោកស្រីខ្លាចអ្វី បើសិនណាគេដឹងថាលក់ស្រីនេះមិនបានរួមដំណេកជាមួយប្តីលោកស្រីទេនោះ? ឆ. ចាស អត់បានរួមដំណេកទេ ព្រោះខ្ញុំខ្លាច ខ្ញុំធម្មតាស្រីយើង មិនមែនការភ្លាម រឹបភ្លាមនោះទេ។ ខ្ញុំញ័រដៃញ័រជើងណាស់ ខ្ញុំខ្លាច ខ្ញុំឱ្យប្តីខ្ញុំលាក់ការណ៍ ថាលាក់ការណ៍ឱ្យជិតទៅ ក៏បានលាក់ការណ៍ជិតរហូតដល់សព្វថ្ងៃចាស។ ស. [...] ខ្ញុំយល់។ ប្រហែល ជាសំណួរខ្ញុំ សួរទៅ វាមិនបានច្បាស់មើលទៅ ប៉ុន្តែខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកស្រីខ្លាចរហូតថាត្រូវតែ លាក់ការណ៍ សម្ងាត់ ដោយសារថាមិនបានរួមសង្វាសជាមួយគ្នា? បើសិនណា ខ្មែរក្រហមរកឃើញថា រូបស្រីហើយនិងប្តីលោកស្រី មិនបាន រួមសង្វាសជាមួយគ្នា លោកស្រីភ័យ តែវាមានអ្វីកើតឡើង បើគេដឹង? ឆ. ចាស ខ្ញុំអត់ដឹងមានអ្វីកើតឡើងទេ បើគេដឹង ចាស ។ កាលហ្នឹង ខ្ញុំប្រាប់ប្តីខ្ញុំថា ខ្ញុំភ័យណាស់ទើបតែការអ៊ីចឹង ខ្ញុំខ្លាចណាស់ កុំប៉ះពាល់ខ្ញុំ។ អ៊ីចឹង នាំគ្នាលាក់ការណ៍សិនទៅ កុំឱ្យគេដឹង ។ ខ្ញុំគ្រាន់តែប៉ុណ្ណឹង"។ ឯកសារ **E1/321.1** មុនម៉ោង [14.27.54]។ សូមមើលផងដែរ "ពូឯងកុំអាលធ្វើអីខ្ញុំ ខ្ញុំខ្លាចណាស់។ដល់ហើយ អ្នកនោះក៏គេអត់បានធ្វើអីខ្ញុំដែរ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

[100] ផាន់ ហ៊ីម៖ ប្រតិចារឹក ថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/468.1** ម៉ោង [09.24.27] និងមុនម៉ោង [09.29.36]។

ចិត្តរស់នៅជាមួយស្វាមី "ក្នុងនាមជាប្តីប្រពន្ធ"[101]។ ករណីនេះមិនអាចឱ្យគេសន្និដ្ឋានបានពីការឈឺចាប់ណាមួយរបស់ស្វាមីលោកស្រី ដោយមូលហេតុនៃទំនាក់ទំនងជិតស្និទ្ធរបស់ពួកគាត់។ ចំណែកលោកស្រី ជា ឌៀប បានឆ្លើយថា ស្វាមីលោកស្រីជាអ្នកសម្រេចក្នុងការរួមភេទ និងបានរៀបរាប់ពីការជួបគ្នានៅរៀងរាល់១០ឬ១៥ថ្ងៃម្តង នៅក្រោយពេលរៀបអាពាហ៍ពិពាហ៍[102]។ ថ្វីបើលោកស្រីបានលើកឡើងពីការឈឺចាប់ផ្ទាល់ខ្លួន ដែលបណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមភេទដោយគ្មានការព្រមព្រៀងពីរូបគាត់ តែលោកស្រីមិនបាននិយាយអ្វីទាល់តែសោះពីស្ថានភាពផ្លូវចិត្តរបស់ស្វាមី[103]។ ដូច្នេះ គេមិនអាចប្រើប្រាស់សក្ខីកម្មរបស់គាត់ ដើម្បីឈានទៅសន្និដ្ឋានថាស្វាមីគាត់បានទទួលរងការឈឺចាប់ណាមួយឡើយ។

៧៦. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានអះអាងថាត្រូវបានស្វាមីរំលោភសេពសន្ថវៈ ដោយរៀបរាប់លម្អិតពីសកម្មភាពរំលោភនោះ[104]។ បន្ទាប់មក ស្វាមីគាត់យកលេសថា គាត់ធ្វើតាមតាមការណែនាំរបស់អង្គការ[105]។ ផ្ទុយទៅវិញ លោកស្រីព្យាយាមបញ្ជាក់ថា ៖ "កាលនុំងគាត់ធ្វើហ្នឹងខ្ញុំមិនដឹងថា អង្គការគេអ្នកឲ្យធ្វើឬអត់ទេ ព្រោះកាលណាដែលគាត់ទៅធ្វើលើខ្ញុំហ្នឹង ដូចយើង

---

[101] ផាន់ ហ៊ីម៖ ប្រតិចារឹក ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ម៉ោង [15.41.03]។ ពួកគេបានរស់នៅជាប្តីប្រពន្ធជាថ្មី បន្ទាប់ពីបានជួបគ្នាវិញនៅលើទឹកដីថៃ ក្រោយពេលវៀតណាមមកដល់ ឯកសារ **E1/467.1** មុនម៉ោង [15.46.19]។ ឯកសារ **E1/468.1** មុនម៉ោង [09.27.58]។

[102] កថាខណ្ឌ ៣៦៤៦ នៃសាលក្រម កំណត់សម្គាល់ជើងទំព័រ ១២៩៤។ ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ម៉ោង [14.07.26] "យ៉ាងរហ័សហើយត្រឹមមួយអាទិត្យឲ្យជួបម្តង មានកន្លះខែ ទៅមួយខែ។ ពេលនោះក៏ធម្មតា ប្តីប្រពន្ធទាល់តែយូរហើយឃើញថាជួបគ្នា ក៏រួមរក្សាគ្នាទៅ។ [...] ស. ជម្រើសនៃការរួមដំណេក ជាជម្រើសរបស់ប្តីអ្នកស្រី ឬក៏ជាជម្រើសរួមគ្នា? ឆ. ជាជម្រើសខាងបុរស"។ សូមមើលផងដែរ ឯកសារ **E1/466.1** មុនម៉ោង [15.34.22] និងម៉ោង [14.07.26]។

[103] ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ម៉ោង [14.17.19]។

[104] ព្រាប សុឃឿន៖ ប្រតិចារឹក ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ចាប់ពីម៉ោង [14.33.35]។ នៅពេលចោទសួរគាត់ពីការរំលោភសេពសន្ថវៈដែលប្រព្រឹត្តដោយស្វាមីរបស់គាត់ដែលគាត់បានរំឭកឃើតបន្តិច គាត់និយាយថា "គាត់បានលើកឡើងថា អ៊ំៗឯងនិយាយទៅ ខ្មាសអីទៀត ការដែលរំលោភអីហ្នឹងអ្វីខ្លះ អ៊ំឯងនិយាយឲ្យអស់មក។ គាត់និយាយថា កាលណាខ្មាស យើងមិនមានភស្តុតាងជាក់លាក់ទេ អ៊ីចឹងនិយាយឲ្យច្បាស់លាស់ ដល់ទៅ ក៏ខ្ញុំក៏និយាយ តាមដំណើរដើមទងរហូតចប់ជម្រាបគាត់ទៅចាស"។ ប្រតិចារឹក ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ម៉ោង [11.31.01]។

[105] ព្រាប សុឃឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោង [11.44.52] បន្ទាប់ពីម៉ោង [13.53.46]។

មនុស្សកំរោលដែរហ្នឹង គាត់ទៅបំពារបំពានលើខ្ញុំដើម្បីសម្រាប់គោលបំណងគាត់ដែរ។ [...]អ៊ីចឹងខ្ញុំមិនដឹងថា អង្គការគេប្រើគាត់ធ្វើ ឬក៏គាត់ធ្វើខ្លួនគាត់ទេ"[106]។ លោកស្រីបន្ថែមទៀតថា៖ "ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា ការបញ្ហាមិនមានអ្នកណាបញ្ជាខ្ញុំទេ កាលហ្នឹងខ្ញុំនៅតែការពារខ្លួនមិនព្រមរួមរក្ស។ កាលនុ៎ងដែលការចាប់រំលោភពីប្ដីខ្ញុំហ្នឹង [...]អ៊ីចឹងគឺខ្ញុំអត់មានអ្នកណាមកបង្ខំឲ្យខ្ញុំរួមរក្ស អត់មានទេ"[107]។ ពាក្យពេជន៍របស់គាត់មិនអាចឱ្យគេសន្និដ្ឋានបានថាស្វាមីរបស់លោកស្រីបានទទួលរងការឈឺចាប់បែបណាមួយឡើយ ដែលលោកស្រីបង្ហាញថាស្វាមីជាអ្នកផ្ដើមគំនិតនៃការរួមរ័កនេះ។

៧៧. ម្យ៉ាងវិញទៀត ព្រាប សុឃឿន បញ្ជាក់ថា ក្រោយរៀបអាពាហ៍ពិពាហ៍រួច គូស្រករជាច្រើនបានរស់នៅចុះសម្រុងនឹងគ្នា "ចាស នៅក្នុងនុ៎ងការហើយទៅ មានអ្នកត្រូវគ្នាហ្នឹងភាគច្រើន។ ចាស គេយល់ថា គេបានទទួលការទុកដាក់គ្រួសារពីអង្គការ គេគោរពអង្គការវិន័យ គេត្រូវរ៉ូវគ្នាច្រើន។ គេរស់នៅនឹងគ្នា ជុំគ្នាសុខដុមរមនាទៅ [...]តែមានគូភាគច្រើន គាត់គិតថាៗ អង្គការឲ្យគាត់មានគ្រួសារគឺអនាគតគាត់ គាត់គោរពអង្គការដោយពេញលេញ គាត់អត់មានប្រឆាំង"[108]។

៧៨. យូ វ៉ាន់ ដែលជាកូនចៅរបស់ ប្រាក់ យុត នៅស្រុកកំពង់សៀម បានលើកឡើងពីការរៀបអាពាហ៍ពិពាហ៍ដែលមានការព្រមព្រៀងពីសាមីខ្លួន ដោយបញ្ជាក់ថា បុរសៗជាអ្នកស្នើសុំរៀបការទៅតាមប្រពៃណី"[109]។ គាត់បានបញ្ជាក់ជាអាទិ៍ថា បុរសជាច្រើនបានមកតវ៉ាចំពោះមុខគាត់ពីបញ្ហាដែលភរិយារបស់ពួកគេបដិសេធមិនព្រមរួមមេត្រី[110]។

---

[106] ព្រាប សុឃឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** មុនម៉ោង [15.14.49] និងម៉ោង [15.30.51]។

[107] ព្រាប សុឃឿន៖ ប្រតិចារឹក ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** បន្ទាប់ពីម៉ោង [13.51.22]។

[108] ប្រតិចារឹក ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** មុនម៉ោង [09.37.04]។

[109] យូ វ៉ាន់៖ ប្រតិចារឹក ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៦ ឯកសារ **E1/376.1** សវនាការអសាធារណ: មុនម៉ោង [14.34.14] ។ ប្រតិចារឹក ថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០១៦ ឯកសារ **E1/378.1** សវនាការអសាធារណ: បន្ទាប់ពីម៉ោង [11.28.27]។ ប្រតិចារឹក ថ្ងៃទី១៨ ខែមករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** សវនាការអសាធារណ: ក្រោយម៉ោង [11.32.17] "គឺខ្ញុំទម្លាប់ខ្មែរតែអ៊ីចឹង មិនដែលស្ត្រីស្នើបុរសទេ មានតែបុរសស្នើស្ត្រី"។

[110] ប្រតិចារឹក ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៦ ឯកសារ **E1/376.1** មុនម៉ោង [15.40.24] នៅពេលប្រៀបធៀប ជាមួយកំណត់ហេតុស្តាប់ចម្លើយ គាត់ឆ្លើយថា "មាន ប៉ុន្តែអប់រំមួយដង ជាពីរដងទៅក៏វាព្រមទៅ វាអត់មានបែកគ្នាទេ"។ សូមមើលផងដែរ

៧៩. **សុន វុត** បានឆ្លើយថា គាត់បានបដិសេធសំណើសុំរៀបការដោយពុំមានរងផលវិបាកអ្វីឡើយ[111]។ គាត់បានលើកឡើងពីការឃ្លាំមើលគូស្វាមីភរិយាទើបរៀបការរួចដែលជាយុទ្ធជន នៅក្នុងកងឃោធា និងការតាមដានគូស្វាមីភរិយា ក្នុងករណីមិនចុះសម្រុងនឹងគ្នា៖ "អានេះគេតាមថ្នាក់លើ គេយកទៅអប់រំ។ បើស្រីមិនស្រឡាញ់ បុរសស្រឡាញ់ អានេះគេអប់រំ អប់រំស្រី"[112]។ ទោះបីជាគាត់បានលើកឡើងថា មានស្វាមីភរិយាមួយគូត្រូវបានយកទៅអប់រំឱ្យយល់ព្រមទទួលយកការរៀបការក៏ដោយ ផ្ទុយទៅវិញ គាត់បានឆ្លើយថា ពួកគេមិនត្រូវបាន "យកទៅវៃ" ទេ ហើយក្រោយមក ពួកគេបានបែកគ្នា[113]។ ដូច្នេះ សក្ខីកម្មរបស់គាត់មិនផ្តល់នូវធាតុផ្សំអ្វីសោះឡើយ ទាក់ទងនឹងការឈឺចាប់ដែលបុរសទទួលរង ដោយសារតែការរួមដំណេក។

៨០. ចុងក្រោយ សក្ខីកម្មរបស់ មុំ វុន បានបញ្ជាក់ថា ពួកឈ្លបបានបង្ខំរូបគាត់ឱ្យរួមរ័កនៅចំពោះមុខពួកគេ[114]។ លោកស្រីមិនបានបញ្ជាក់ពីឧប្បត្តិការណ៍កើតឡើងចំពោះស្វាមីលោកស្រី នៅពេលផ្តល់សក្ខីកម្មឡើយ[115]។ ទោះជាយ៉ាងណាក្តី សក្ខីកម្មរបស់គាត់មិនអាចឱ្យអង្គជំនុំជម្រះមានភស្តុតាងដើម្បីឈានទៅសន្និដ្ឋានពីកម្រិតនៃការឈឺចាប់ដែលស្វាមីលោកស្រីបានទទួលរងឡើយ។

៨១. ការពិនិត្យលើធាតុផ្សំនៃភស្តុតាងដែលប្រើដោយអង្គជំនុំជម្រះ ដើម្បីសន្និដ្ឋានពីការទទួលរងការឈឺចាប់ធ្ងន់ធ្ងររបស់ស្ត្រី បង្ហាញថា ធាតុផ្សំទាំងនោះមិនគ្រប់គ្រាន់ដើម្បីកំណត់កម្រិតធ្ងន់ធ្ងរនៃការឈឺ

---

កថាខណ្ឌ៣៦៥៦ នៃសាលក្រម និងផ្នែកខាងក្រោមនៃចម្លើយរបស់ ប្រាក់ យុត ក្នុងសក្ខីកម្មរបស់ យូ វ៉ាន។

[111] សុន វុត៖ ប្រតិចារឹក ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/411.1** ក្រោយម៉ោង [14.38.04]។ ប្រតិចារឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/412.1** ក្រោយម៉ោង [09.07.49]។

[112] សុន វុត៖ ប្រតិចារឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/412.1** ក្រោយម៉ោង [09.11.11]។

[113] សុន វុត៖ ប្រតិចារឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/412.1** មុនម៉ោង [09.40.08] "បាទ បដិសេធដូចខ្ញុំជម្រាបប្រាប់លោកប្រធានមុនហើយ ដូចថា មិត្តបាន ហើយនិង មិត្តនារ ដែលគេបដិសេធគេមិនស្រឡាញ់គ្នា ហើយយកទៅកែអប់រំដែរ វាមិនមានថាយកទៅវៃ ឬអីទេ ប៉ុន្តែមានអង្គការគឺថា វាអប់រំណែនាំ ដើម្បីឱ្យសម្រួលគ្នាវិញ ប៉ុន្តែសាមីខ្លួននោះ ក៏គេមិនសុខព្រម ប៉ុន្តែមិនដឹងថារបៀបម៉េច វាបែកគ្នា"។

[114] មុំ វុន៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ម៉ោង [13.46.09]។

[115] ការរួមដំណេករបស់ពួកគេ ក្រោយហេតុការណ៍បានកើតឡើង៖ ប្រតិចារឹក ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ក្រោយម៉ោង [15.10.14] "[...] ក្នុងបីខែកន្លះហ្នឹង គេមក ហើយគេចូលមករួមភេទជុំយើង"។

ចាប់ដែលបុរសបានទទួលរង បណ្តាលមកពីអំពើហិង្សាផ្លូវភេទ នៅក្នុងក្របខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍នោះឡើយ។ ការបន្ទោសអង្គជំនុំជម្រះលើចំណុចនេះ ពុំមានមូលដ្ឋានទេ ហើយដូច្នេះត្រូវដកចេញ។

## ២.២. សក្ខីកម្ម និងរបាយករណ៍សិក្សាស្តីពីការដាក់សម្ពាធ និងការបង្ខំទៅលើបុរស

៨២. ម្ចាស់បណ្តឹងសាទុក្ខបានស្តីបន្ទោសអង្គជំនុំជម្រះចំពោះការមិនបានពិចារណាពេញលេញលើសក្ខីកម្ម និងរបាយការណ៍សិក្សា (ដែលបានដាក់បញ្ចូលក្នុងសំណុំរឿង) ដែលបានរំលេចពីការរងសម្ពាធផ្សេងៗពីសំណាក់បុរសៗ ក្នុងការផ្សំដំណេក និងការព្រួយបារម្ភរបស់ពួកគេចំពោះផលវិបាកក្នុងករណីមិនរួមដំណេក[116]។

៨៣. អាស្រ័យហេតុនេះ ចំណុចទីមួយ ម្ចាស់បណ្តឹងសាទុក្ខបានសង្កត់ធ្ងន់លើសក្ខីកម្មជាលាយលក្ខណ៍អក្សរចំនួន៤ របស់បុរសបីរូប (សុំ ប៉េត, វ៉ាត ផាត, មូល អេង) និងស្ត្រីមួយរូប (កែវ ផារី) ដែលសុទ្ធតែចេញមកពីសំណុំរឿង០០៣ និង០០៤[117]។

៨៤. សុំ ប៉េត អះអាងថាលោកមានការព្រួយបារម្ភដោយត្រូវរៀបការជាមួយនារីដែលខ្លួនមិនស្គាល់ ៖ "សម្រាប់រូបខ្ញុំផ្ទាល់មានអារម្មណ៍លំបាក ដោយសារយើងមិនស្គាល់ចិត្តគ្នា។ ចំពោះប្រពន្ធរបស់ខ្ញុំក៏មានអារម្មណ៍ភ័យខ្លាច តែព្យាយាមសម្របសម្រួលខ្លួនតាមកាលៈទេសៈ"[118]។ លោកបានបន្ថែមថា ផ្ទុយពីគូស្រករផ្សេងទៀត លោកនិងភរិយា មិនត្រូវបានគេយកទៅអប់រំទេ។ លោកនិយាយថាលោកត្រូវរួមដំណេក ដោយខ្លាចទទួលរងការចោទប្រកាន់ថាប្រឆាំងនឹងអង្គការ ក្រោយពីបានសម្រេចចិត្តទៅរស់នៅផ្ទះម្តាយរបស់គាត់ជាមួយភរិយា[119]។ ក៏ប៉ុន្តែ លោកមិនបានលើកឡើងពីការ

---

[116] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥-៣៧។

[117] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់ជើងទំព័រ ១០២ កថាខណ្ឌ ៣៥។

[118] កំណត់ហេតុស្តាប់ចម្លើយសាក្សី សុំ ប៉េត ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ E3/9824 ស./ឆ.៣១ និង ស./ឆ.៤១។

[119] កំណត់ហេតុស្តាប់ចម្លើយសាក្សី សុំ ប៉េត ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ E3/9824 ស./ឆ.៤៥៖ "[...] តើប្តីប្រពន្ធលោកធ្វើបែបនេះដោយសារតែគេបានអប់រំនៅពេលរៀបការ ឬក៏មុនពេលរៀបការថា អ្នកដែលអង្គការរៀបចំឱ្យមានគ្រួសារត្រូវតែរួមរស់នៅជាមួយគ្នា បើពុំដូច្នេះទេ គេនឹងចោទថា មិនគោរពវិន័យអង្គការ?" ឆ.៤៥ [...] យើងត្រូវតែធ្វើការ បើ

ទទួលរងនូវការឈឺចាប់ជាយថាហេតុតាមផ្លូវកាយ ឬផ្លូវចិត្ត បណ្ដាលមកពីទំនាក់ទំនងផ្លូវភេទរបស់គូស្រករគាត់ទេ។

៨៥. វ៉ាត ផាត ជាអតីតយុទ្ធជន ដែលបានរៀបការ នៅក្នុងពិធីដាច់ដោយឡែកតែឯងមួយ។ លោកបានគូសបញ្ជាក់ថា លោកទទួលបានសិទ្ធិឈប់សម្រាកចំនួនពីរសប្ដាហ៍បន្ទាប់ពីរៀបការរួច និងមានអារម្មណ៍ថាត្រូវបានគេបង្ខំឱ្យរួមដំណេក។ ទន្ទឹមនឹងនេះ លោកអះអាងថា លោកបានគំរាមសម្លាប់នីរសារម្នាក់ ដែលមកតាមដានគាត់នៅពេលយប់ ហើយនីរសារនោះលែងហ៊ានត្រឡប់មកទៀតនាពេលក្រោយមក។ លោកមិនបានលើកឡើងពីការទទួលរងនូវការឈឺចាប់ណាមួយដែលបណ្ដាលមកពីការផ្សំដំណេក។ លោករស់នៅសព្វថ្ងៃជាមួយភរិយា និងកូន[120]។

៨៦. មួល អេង អតីតយុទ្ធជនភូមិភាគនិរតី ដែលបានរៀបការជាមួយនារីកម្មាភិបាលខ្មែរក្រហមម្នាក់និយាយថា លោកមានអារម្មណ៍ថាត្រូវបានគេបង្ខំឱ្យផ្សំដំណេក ពីព្រោះ "មនុស្សដែលនៅក្បែរៗនោះ" បានតាមដានរឿងរ៉ាវគ្រប់យ៉ាង ក្រែងមានបញ្ហាអ្វីកើតឡើង[121]។ រយៈពេលដប់ថ្ងៃជាងក្រោយពេលរៀបការ គាត់ត្រូវបានគេបញ្ជូនទៅធ្វើការនៅភូមិភាគពាយ័ព្យជាមួយភរិយា[122]។ លោកមិនបានលើកឡើងពីការទទួលរងនូវការឈឺចាប់ណាមួយ ដែលបណ្ដាលមកពីទំនាក់ទំនងផ្លូវភេទជាមួយភរិយាលោកឡើយ។

---

ពុំនោះទេ គេចោទថា យើងប្រឆាំងនឹងអង្គការ។ ដោយមានបទពិសោធន៍ពីមុនៗផង ដូច្នេះ ក្រោយពីគេរៀបការឱ្យហើយ យើងទាំងអស់គ្នាយល់ដោយខ្លួនឯងថា យើងត្រូវតែរួមរស់នៅជាមួយគ្នា ជាប្ដីប្រពន្ធ" ស./ឆ.៤៣៖ គឺប្ដីប្រពន្ធទើបរៀបការរួចជាអ្នកសម្រេចដោយខ្លួនឯងថានៅរស់នៅឯណាក្រោយរៀបការរួច ហើយចំពោះករណីរបស់គាត់ គាត់សម្រេចចិត្តរស់នៅខាងផ្ទះម្ដាយរបស់គាត់។

[120] កំណត់ហេតុស្ដាប់ចម្លើយសាក្សី វ៉ាត ផាត ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E3/9822 ស./ឆ.៣៥២, ស./ឆ.៣៥៨៖ "ស.៖ តើលោកមានអារម្មណ៍ថា ត្រូវគេបង្ខំឱ្យរួមដំណេកជាមួយនឹងប្រពន្ធរបស់លោកដែរឬទេ? ឆ.៣៥៨៖ ខ្ញុំមានអារម្មណ៍ថាត្រូវគេបង្ខំដែរ ដូច្នេះខ្ញុំត្រូវរួមដំណេកជាមួយប្រពន្ធរបស់ខ្ញុំ រហូតដល់មានកូនម្នាក់ដល់សព្វថ្ងៃនេះ" ស./ឆ.១៩៨៖ គាត់បានទៅរស់នៅជាមួយប្រពន្ធរបស់គាត់ ក្រោយពេលគាត់ចេញពីគុកព្រៃសនៅឆ្នាំ១៩៨៤។

[121] កំណត់ហេតុស្ដាប់ចម្លើយសាក្សី មួល អេង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ E3/9833 ស./ឆ.២១២។ សូមមើលផងដែរ ស./ឆ.២១៣-២១៤។

[122] កំណត់ហេតុស្ដាប់ចម្លើយសាក្សី មួល អេង ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ E3/9833 ស./ឆ.២១៥-២១៦។

៨៧. កែវ ធារី អះអាងថា ស្វាមីលោកស្រីត្រូវធ្វើតាមបញ្ជារបស់អង្គការ និងរៀបការ[123]។ ទោះបីលោកស្រីបានលើកឡើងពីការភ័យខ្លាចនៅពេលដំបូងក៏ដោយ ក៏ប៉ុន្តែ បន្ទាប់មក លោកស្រីបានអះអាងថា បន្តិចម្តងៗ លោកស្រី និងស្វាមី បានបណ្តុះមនោសញ្ចេតនារវាងគ្នាទៅវិញទៅមក៖ "គឺយើងដេកនៅដូចប្តីប្រពន្ធគេដទៃទៀតដែរ ហើយយើងសប្បាយចិត្តពេលបានជួបគ្នាម្តងៗ"[124]។ លោកស្រីបន្ថែមថា ជួនកាល ស្វាមីលោកស្រីបានភូតកុហកប្រធានកង ដើម្បីមកជួបគាត់នៅផ្ទះ[125]។ ដូច្នេះ សក្ខីកម្មរបស់គាត់មិនបានលើកឡើងពីការឈឺចាប់ណាមួយដែលគាត់ និងស្វាមីបានទទួលរងដែលបណ្តាលមកពីទំនាក់ទំនងផ្លូវភេទឡើយ។ វាមិនមែនគ្មានសារៈសំខាន់នោះទេ ក្នុងការលើកឡើង ដូចការកត់សម្គាល់របស់ម្ចាស់បណ្តឹងសាទុក្ខផ្ទាល់[126] ថា កំណត់ហេតុស្តាប់ចម្លើយសាក្សី កែវ ធារី គឺជាកំណត់ហេតុស្តាប់ចម្លើយតែមួយគត់ ដែលអង្គជំនុំជម្រះមិនបានលើកឡើងនៅក្នុង

---

[123] កំណត់ហេតុស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9662**។ សូមមើលផងដែរ ស./ឆ.៤៤ អំពីកាតព្វកិច្ចត្រូវគោរពអង្គការ។ សូមមើល ស./ឆ.៤៥ ទាក់ទងនឹងការឃ្លាំមើល។ កែវ ធារី បញ្ជាក់ថា លោកស្រីមិនបានឃើញគេតាមដានលោកស្រីដោយផ្ទាល់ភ្នែកទេ ប៉ុន្តែ គឺ "ចាស់ទុំ" និងម្តាយរបស់លោកស្រីដែលបានប្រាប់លោកស្រីអំពីរឿងនេះ។ សូមមើល ស./ឆ.៤០-៤៣ ទាក់ទងនឹងការដែលថាលោកស្រីមិនដឹងអំពីរឿងរួមដំណេក និងអន្តរាគមន៍របស់ម្តាយលោកស្រី៖ "ពួកគាត់ព្យាយាមនិយាយសម្របសម្រួលខ្ញុំឱ្យព្រមនៅជាមួយគាត់។ ពេលដែលម្តាយខ្ញុំចេញទៅ ប្តីខ្ញុំ និងខ្ញុំក៏ដេកនៅជាមួយគ្នា"។

[124] កំណត់ហេតុស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9662** ស./ឆ.៥៥-៥៩ ជាអាទិ៍ ស./ឆ.៥៩៖ "បន្ទាប់ពីយើងរៀបការហើយ បានចាស់ទុំមកសម្របសម្រួល និងដឹងឮ។ ខ្ញុំមានអារម្មណ៍ស្រឡាញ់គាត់គឺក្រោយពេលយើងរៀបការបាន១អាទិត្យ។ ទោះបីយើងមិនបានដេកជាមួយគ្នារៀងរាល់ថ្ងៃក៏ដោយ គឺខ្ញុំស្រឡាញ់ប្តីខ្ញុំ"។

[125] កំណត់ហេតុស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9662** ស./ឆ.៥៥៖ "[...] ឧទាហរណ៍៖ ប្រសិនបើប្តីខ្ញុំចង់មកលេងផ្ទះ ជួនកាលពេលដែលគាត់ចង់មកលេងផ្ទះ គាត់មិនអាចប្រាប់មេកងតាមត្រង់ថា គាត់ចង់មកជួបខ្ញុំទេ គាត់ត្រូវកុហកថា គាត់ត្រូវការមកយកខោអាវនៅផ្ទះជាដើម ទើបគេអនុញ្ញាតឱ្យគាត់មក"។ ស./ឆ.៨៦៖ បន្ទាប់ពីចំណាយពេលជាច្រើនឆ្នាំរស់នៅជាមួយគ្នាហើយ ពួកគាត់មានអារម្មណ៍ថាដូចជាប្តីប្រពន្ធផ្សេងទៀតដែលរៀបការជាមួយគ្នាដោយការជ្រើសរើសរបស់ខ្លួន ហើយលោកស្រីបាននិយាយលេងជាមួយនឹងប្តីលោកស្រីថា ពួកគាត់រៀបការមិនពេញលក្ខណៈ ដោយសារនៅសម័យនោះ ពួកគាត់រៀបការដោយមិនធ្វើតាមប្រពៃណីត្រឹមត្រូវ។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឯកសារ **E3/4963** ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ លោកស្រីមិនបានលើកឡើងអំពីការរៀបការដោយបង្ខំថាជាការឈឺចាប់របស់លោកស្រីទេ។

[126] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់ជើងទំព័រ ១០២ កថាខណ្ឌ ៣៥។

សាលក្រមជាលាយលក្ខណ៍របស់ខ្លួន នៅក្នុងផ្នែករៀបអាពាហ៍ពិពាហ៍។ ក្រុមមេធាវីការពារក្តី នឹងត្រឡប់មកនិយាយពីបញ្ហានេះ នៅក្នុងសារណាបណ្តឹងសាទុក្ខ។

៨៨. ចំណុចទីពីរ ម្ចាស់បណ្តឹងសាទុក្ខបានរំលឹកពីការនិទានរបស់ស្ត្រីមិនស្គាល់អត្តសញ្ញាណម្នាក់ ដកស្រង់ចេញពីសៀវភៅរបស់ Kasumi NAKAGAWA[127] ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងរឿងរ៉ាវរបស់ កែវ ធារី ដែរ។ នៅក្នុងការនិទាន ស្ត្រីម្នាក់នោះបានយល់ព្រមរួមភេទនៅរាត្រីទីបីក្រោយរៀបការរួច និងបន្ទាប់ពីស្វាមីគាត់បានប្រាប់ថា គាត់មានការបារម្ភពីភរិយា ដោយសារនាងបដិសេធមិនព្រមរួមដំណេក[128]។ នៅត្រង់ចំណុចនេះទៀតសោត ដោយមិនបាច់និយាយពីភាពអាចជឿទុកចិត្តបាននៃការនិទានបែបអនាមិកនោះ គេពិបាកនឹងប្រមើលឃើញថា តើត្រង់ចំណុចណាដែលជាភ័ស្តុតាងអំពីទម្ងន់នៃការឈឺចាប់ ឬឧប្បត្តិការណ៍នៃអំពើហិង្សាផ្លូវភេទប៉ះពាល់ដល់ស្វាមីរបស់គាត់។

៨៩. ចំណុចទីបី ម្ចាស់បណ្តឹងសាទុក្ខផ្តោតទៅលើការនិទានរបស់បុគ្គលមិនស្គាល់អត្តសញ្ញាណនៅក្នុងឯកសារសិក្សារបស់អ្នកស្រាវជ្រាវ (នៅក្រៅបរិបទតុលាការ) ដែលមិនបានចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ[129]។ ដោយមូលហេតុនេះ ឯកសារទាំងនេះមានតម្លៃជាភ័ស្តុតាងតិចតួចស្តួចស្តើងខ្លាំង ឬគ្មានតម្លៃអ្វីទាំងអស់។

---

[127] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់ជើងទំព័រ ១០២ កថាខណ្ឌ ៣៥។

[128] Kasumi NAKAGAWA អំពើហិង្សាលើយេនឌ័រនៅអំឡុងរបបខ្មែរក្រហម ខែធ្នូ ឆ្នាំ២០០៨ ឯកសារ **E3/2959**, ERN KH 00738345។

[129] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កំណត់សម្គាល់ជើងទំព័រ ១០២-១០៣ កថាខណ្ឌ ៣៥៖ សៀវភៅនិពន្ធដោយ Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម* ខែមីនា ឆ្នាំ២០១៤ ឯកសារ **E3/9240**, ERN EN 00992283 ; Bridgette Toy Cronin *"ខ្ញុំចង់ប្រាប់អ្នក"៖ រឿងទាក់ទងនឹងការរំលោភបំពានផ្លូវភេទក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ* ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E3/3416**, ERN KH 00721384 ; Theresa De Langis និងគូកន *កែប្រែខ្លួនប្រាណដូចខ្មោច៖ ការសិក្សាពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម* ឆ្នាំ២០១៤ ឯកសារ **E3/9614**, ERN EN 010378471។

៩០. ចំណុចទីបួន ម្ចាស់បណ្តឹងសាទុក្ខសង្កត់ធ្ងន់លើការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន[130] ដូចបានលើកឡើងពីខាងដើម[131]។ ខណៈដែលសហព្រះរាជអាជ្ញាគួរតែអាចចោទសួរគាត់នៅក្នុងសវនាការពីផលប៉ះពាល់នៃអង្គហេតុទាំងនេះទៅលើស្វាមីគាត់ (ទោះបីជាករណីនេះ វានៅតែជាការលើនិយាយតគ្នាក៏ដោយ) ម្ចាស់បណ្តឹងបែរជា "ផ្តល់សក្ខីកម្ម" ជំនួសឱ្យស្វាមីគាត់នៅក្នុងបណ្តឹងសាទុក្ខនេះ។

៩១. ផ្អែកលើធាតុផ្សំនៃភ័ស្តុតាងដែលអង្គជំនុំជម្រះទំនងជាមិនបានយកចិត្តទុកដាក់នេះ វាស្តែងឱ្យឃើញថា អំណះអំណាងរបស់សហព្រះរាជអាជ្ញាដើម្បីគាំទ្រដល់បណ្តឹងសាទុក្ខ មិនមានមូលដ្ឋាននោះទេ។ ជាក់ស្តែង ម្ចាស់បណ្តឹងផ្អែកលើភ័ស្តុតាងមិនផ្ទាល់ ដែលមិនត្រឹមតែគ្មានភាពពាក់ព័ន្ធប៉ុណ្ណោះទេ តែថែមទាំងមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ ការពិនិត្យលម្អិតទៅលើសក្ខីកម្ម ការអះអាង និងការនិទានផ្សេងទៀត បង្ហាញពីកង្វះខាតភ័ស្តុតាងស្តីពីការឈឺចាប់ដែលទទួលរងដោយបុរសៗរងគ្រោះដោយអំពើហិង្សាផ្លូវភេទ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ទោះជាយ៉ាងណាក្តី គ្មានធាតុផ្សំនៃភ័ស្តុតាងណាមួយអាចបញ្ជាក់ពីកម្រិតនៃភាពធ្ងន់ធ្ងរដែលអោយកំណត់បានថា ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សទេ។

## ៣. គ្មានភាពផ្ទុយគ្នាពីការកត់សម្គាល់ផ្សេងៗរបស់អង្គជំនុំជម្រះ

៩២. ដូច្នេះ វាជារឿងមិនត្រឹមត្រូវដែលម្ចាស់បណ្តឹងសាទុក្ខស្តីបន្ទោសដល់អង្គជំនុំជម្រះថាបានដើរផ្ទុយពីធាតុផ្សំនៃភ័ស្តុតាងដែលបានបង្ហាញ និងផ្ទុយពីការកត់សម្គាល់របស់ខ្លួនផ្ទាល់ ដោយវិនិច្ឆ័យថាធាតុផ្សំទាំងនោះមានលក្ខណៈ "មិនគ្រប់គ្រាន់ដើម្បីកំណត់ថាមានការឈឺចាប់ធ្ងន់ធ្ងរ" ដែលបុរសៗបានទទួលរង[132]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនអាចវិនិច្ឆ័យផ្សេងពីនេះ បើទោះជាមានសេចក្តីសន្និដ្ឋានទាំងប្រាំដែលអាចទិទៀនបានដែលសហព្រះរាជអាជ្ញាបានយកមកសំអាង ដោយពិចារណាលើធាតុផ្សំនៃភ័ស្តុតាងសម្រាប់ធ្វើជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានទាំងប្រាំនោះ។

---

[130] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៦-៣៧។

[131] សូមមើល ខាងលើ កថាខណ្ឌ ៨០។

[132] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦។

**សេចក្តីសន្និដ្ឋានដែលថា បុរសៗ "ត្រូវបានបង្ខំឱ្យរួមភេទ"[133]**

៩៣. បើតាមការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ បុរស និងស្ត្រីត្រូវបានបង្ខំឱ្យរួមភេទ។ ក៏ប៉ុន្តែ ដូចអ្វីដែលយើងបានឃើញពីខាងលើ[134] ការវិភាគលើភ័ស្តុតាងគាំទ្រដល់ការកត់សម្គាល់របស់អង្គជំនុំជម្រះ បង្ហាញថា ភាគច្រើនជាស្ត្រីដែលបានផ្តល់សក្ខីកម្មពីបទពិសោធន៍ផ្ទាល់ខ្លួន មិនបានលើកឡើង ឬផ្តល់តម្រុយគ្រប់គ្រាន់ណាមួយស្តីពីឧប្បត្តិហេតុជាយថាហេតុកើតមានលើស្វាមី ដែលនាំទៅដល់ការសន្និដ្ឋានពីការឈឺចាប់ដែលបុរសៗទទួលរង រហូតដល់កម្រិតតម្រូវមួយដើម្បីកំណត់បទឧក្រិដ្ឋក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត។

**សេចក្តីសន្និដ្ឋានដែលថា បុរសៗ "ត្រូវបានបង្ខំឱ្យបង្ខំភរិយារបស់ខ្លួនរួមភេទ ដែលបង្កការឈឺចាប់ធ្ងន់ធ្ងរ ឬការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្ត ដល់ស្ត្រី និងបង្កជាការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស"[135]**

៩៤. យើងគួររំលឹកនៅពេលនេះថា បញ្ហានេះត្រូវបានលើកយកពិភាក្សាយ៉ាងលឿនតែម្តងគត់ នៅពេលដែល Kasumi NAKAGAWA បាកបញ្ចេញមតិទូទៅ ដោយពន្យល់ថា លោកស្រីមិនបានផ្តោតការសិក្សាស្រាវជ្រាវពីបុរសទេ[136]។ ដោយសារភ័ស្តុតាងមានភាពខ្វះខាតច្រើនដើម្បីគាំទ្រមតិរបស់គាត់ អង្គជំនុំជម្រះមិនអាចផ្អែកឱ្យបានប្រាកដប្រជាលើមតិនេះ ដើម្បីកំណត់បទឧក្រិដ្ឋក្រោមទម្រង់ជាអំពើអមនុស្សធម៌បានឡើយ។

**សេចក្តីសន្និដ្ឋានដែលថា បុរសៗ "បាន<u>រងសម្ពាធផ្លូវចិត្តធ្ងន់ធ្ងរ</u> ដោយសារការរួមភេទដោយបង្ខំ"[137]**

---

[133] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦ និងកំណត់សម្គាល់ជើងទំព័រ ៧១ យោងទៅកថាខណ្ឌ ៣៦៦០, ៣៦៦១, ៣៦៩១, ៣៦៩២, ៣៦៩៦, ៣៦៩៨ និង ៣៦៩៩ នៃសាលក្រម។

[134] សូមមើលខាងលើ កថាខណ្ឌ ៤៥-៤៩ និងកថាខណ្ឌ ៦០-៨១។

[135] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦ និងកំណត់សម្គាល់ជើងទំព័រ ៧២ យោងទៅកថាខណ្ឌ ៣៦៨៤, ៣៦៩១, ៣៦៩៧, ៣៦៩៨ នៃសាលក្រម។

[136] សូមមើល ខាងលើ កថាខណ្ឌ ៦០-៦២។

[137] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦ (គូសបន្ទាត់ខាងក្រោមនៅក្នុងច្បាប់ដើម) និងកំណត់សម្គាល់ជើងទំព័រ ៧៤ យោងទៅកថាខណ្ឌ ៣៦៨៣ និង ៣៦៨៤ នៃសាលក្រម។

៩៥. យើងគួររំលឹកថា ការកត់សម្គាល់បែបនេះ ស្ថិតនៅក្នុងផ្នែក ១៤.៣.១២.២. *ឧប្បត្តិហេតុនៃការរួមភេទដោយបង្ខំលើជនរងគ្រោះ* ជាអាទិ៍នៅកថាខណ្ឌ ៣៦៨៣ នៃសាលក្រមជាលាយលក្ខណ៍អក្សរ ដែលអង្គជំនុំជម្រះបានសំអាងជាពិសេសលើការឈឺចាប់ជាលក្ខណៈបុគ្គលដែលទទួលរងដោយ ព្រាប សុឃឿន[138]។ ចំណែកការឈឺចាប់ដែលបុរសៗបានទទួលរង ត្រូវបានលើកឡើងក្នុងកថាខណ្ឌ ៣៦៨៤ ដោយផ្អែកតែលើការសន្ធរបស់ Kasumi NAKAGAWA[139] ប៉ុណ្ណោះ។ ក្រុមមេធាវីការពារក្តីសូមយោងលើទល្លីករណ៍ដែលបានបង្ហាញខាងលើ។

## សេចក្តីសន្និដ្ឋានដែលថា បុរសៗ "ត្រូវបានគំរាមសម្លាប់ បើមិនធ្វើតាមការណែនាំរបស់បក្ស"[140]

៩៦. ដើម្បីឈានទៅដល់ការសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះបានយោងម្តងទៀតទៅលើសក្ខីកម្មរបស់ ព្រាប សុឃឿន ដោយចោះៗ។ ដូចបានឃើញពីខាងលើរួចមកហើយ ព្រាប សុឃឿន បាននិយាយបែបនេះ៖ "[...] <u>ខ្ញុំព្រោះកាលណាដែលគាត់ទៅធ្វើលើខ្ញុំហ្នឹង ដូចយើងមនុស្សកំរោលដែរហ្នឹង គាត់ទៅបំពារបំពានលើខ្ញុំដើម្បីសម្រាប់គោលបំណងគាត់ដែរ</u> [...]អ៊ីចឹងខ្ញុំមិនដឹងថា អង្គការគេប្រើគាត់ធ្វើ ឬក៏គាត់ធ្វើខ្លួនគាត់ទេ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)[141]។

៩៧. ម៉្យាងវិញទៀត ក៏មានការយោងទៅកថាខណ្ឌ ៣៦៩៦ នៃសាលក្រមជាលាយលក្ខណ៍អក្សរ ហើយកថាខណ្ឌនេះក៏យោងផងដែរទៅកថាខណ្ឌ ៣៦៥៦ ដល់ ៣៦៥៨ នៅក្នុងផ្នែក ១៤.៣.៨.៣. *ការ*

[138] ផ្នែកនេះនៃសាលក្រមផ្អែកទៅលើចម្លើយរបស់ ព្រាប សុឃឿន NAKAGAWA និង សយ ណារឿន។

[139] NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** ក្រោយ [15.46.22] លោកស្រីផ្តល់យោបល់របស់លោកស្រី បន្ទាប់ពីស្ត្រីពុំស្គាល់អត្តសញ្ញាណម្នាក់បានរៀបរាប់រឿងរ៉ាវ ហើយដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ២៦ និងកថាខណ្ឌ ៣០៖ "វាប៉ះពាល់ជាជីវិតអាពាហ៍ពិពាហ៍ បុរសជាប្តីនោះអាចមានអារម្មណ៍ថា មានកំហុសចំពោះប្រពន្ធ ឬមួយក៏មានការព្រួយបារម្ភ គឺថាក្នុងចិត្តរបស់ខ្លួនហ្នឹង គឺថាគិតថាប្រពន្ធមិនបានស្រឡាញ់ខ្លួនទេ។ វាអាចមានជំងឺបាក់ស្បាតក្នុងចិត្តរបស់គាត់ក្នុងរយៈពេលវែង រហូតដល់តែពេលគាត់ទទួលបានភាពជាបុរសឡើងវិញ ដែលគាត់អាចធានាថា ប្រពន្ធរបស់គាត់ទទួលយកគាត់ជាប្តីបាន" (យើងគូសបន្ទាត់ពីក្រោម)។

[140] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦ និងកំណត់សម្គាល់ជើងទំព័រ ៧៥ យោងទៅកថាខណ្ឌ ៣៦៥៣ និង ៣៦៩៦ នៃសាលក្រមជាលាយលក្ខណ៍អក្សរ។

[141] កថាខណ្ឌ ៣៦៥៣ នៃសាលក្រម លើកឡើងពីករណី ព្រាប សុឃឿន៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** មុនម៉ោង [15.15.30]។ សូមមើលទល្លីករណ៍ខាងលើ ជាអាទិ៍ កថាខណ្ឌ ៧៦ ទាក់ទងនឹងសក្ខីកម្មរបស់គាត់។

*រួមភេទដោយបង្ខំរបស់គូស្វាមី* ដោយសន្និដ្ឋានជាអាទិ៍ថា បុរសក៏ដូចស្ត្រីដែរមានអារម្មណ៍ថាត្រូវបានបង្ខំឱ្យរួមភេទជាមួយស្វាមី/ភរិយាថ្មី ហើយក្នុងករណីមិនធ្វើតាម ពួកគេនឹងត្រូវយកទៅអប់រំ ឬគម្រាមសម្លាប់ ឬដាក់ទណ្ឌកម្ម។ ដើម្បីឈានដល់ការសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះសំអាងលើសក្ខីកម្មរបស់ យូ វ៉ាន់ ប្រាក់ យុត សុន វុត ស៊ូ សុធារី ណុប ធីម អ៊ុំ យឿន និង មុំ វុន[142]។ ក៏ប៉ុន្តែ ដូចបានបង្ហាញខាងលើ នៅកថាខណ្ឌ ៣៦៥៨ អង្គជំនុំជម្រះសំអាងលើអង្គហេតុនៃការរំលោភសេពសន្ថវៈទៅលើស្ត្រី នៅក្រៅបរិបទនៃការជំនុំជម្រះ ដើម្បីស្និដ្ឋានថាមានអំពើហិង្សា និងការបង្ខិតបង្ខំ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ និងការផ្សំដំណេក[143]។

៩៨. មូលដ្ឋានមិនរឹងមាំរបស់អង្គជំនុំជម្រះទាំងនេះ មិនអាចឱ្យអង្គជំនុំជម្រះទៅឆ្លាយពាក់ព័ន្ធនឹងស្ថានភាពបុរសៗឡើយ។

**សេចក្តីសន្និដ្ឋានដែលថា បុរសៗ "មានការព្រួយបារម្ភពីអាយុជីវិតផ្ទាល់ខ្លួន បើមិនរួមភេទជាមួយភរិយារបស់ពួកគេ"[144]**

៩៩. ការសន្និដ្ឋាននេះផ្អែកលើមូលដ្ឋានមិនច្បាស់លាស់ដូចខាងដើមដែរ។ ដូច្នេះ វាជាការសមហេតុផលដែលសេចក្តីសន្និដ្ឋាននេះមិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានបានថាមានការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ដើម្បីឈានទៅកំណត់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌។

[142] សូមមើល ខាងលើ កថាខណ្ឌ ៧៨, ៦៥, ៧៩, ៤៦, ៦៧, ៧១ និង ៨០។

[143] ករណីរំលោភសេពសន្ថវៈលើ អ៊ុំ យឿន និង មុំ វុន ដែលស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ៖ អ៊ុំ យឿន ប្រហែលជាត្រូវមេកងរបស់ប្តីរបស់លោកស្រីរំលោភ បន្ទាប់ពីប្តីរបស់លោកស្រីបានប្តឹងមេកងនោះពីរឿងលោកស្រីបដិសេធមិនព្រមរួមដំណេកជាមួយគាត់៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1**។ មុំ វុន អះអាងថាត្រូវសមមិត្តរំលោភ មុនលោកស្រីរៀបការ៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/475.1**។

[144] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦ និងកំណត់សម្គាល់ជើងទំព័រ ៧៦ ដែលយោងទៅកថាខណ្ឌ ៣៦៩៦ នៃសាលក្រម៖ ដូច្នេះ សូមមើល ខាងលើ កថាខណ្ឌ ៩៧។

១០០. ដូចយើងបានឃើញពីខាងលើរួចមកហើយ ក្នុងការលើកឡើងពីស្ថានភាពផ្លូវច្បាប់អន្តរជាតិនៅសម័យនោះ[145] ការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលថាការបង្ខំបុរសឱ្យរួមភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបង្កជាការប៉ះពាល់ធ្ងន់ធ្ងរដល់ភាពថ្លៃថ្នូររបស់មនុស្ស គឺជាការមិនត្រឹមត្រូវ។ ម្យ៉ាងវិញទៀត នៅប្រទេសកម្ពុជារវាងឆ្នាំ១៩៧៥-១៩៧៩ នៅក្នុងទស្សនាទានជាប្រពៃណីក្នុងវប្បធម៌ខ្មែរ បុរសមានឥទ្ធិពលគ្របដណ្តប់លើស្ត្រី ជាពិសេសនៅក្នុងកិច្ចការគ្រួសារ និងនៅក្នុងសង្គមជាទូទៅ។ ឧប្បត្តិហេតុនៃការរួមភេទនៅក្នុងទស្សនៈទូទៅ មានលក្ខណៈខុសគ្នា រវាងបុរស និងស្ត្រី។

១០១. ការពិនិត្យតែទៅលើផ្នែក ១៤.៣.១២.២. *ឧប្បត្តិហេតុនៃការរួមភេទដោយបង្ខំទៅលើជនរងគ្រោះ* មានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញពីអវត្តមាននៃឧប្បត្តិហេតុទទួលរងដោយបុរស ក្នុងកម្រិតធ្ងន់ធ្ងរណាមួយ ដែលអាចកំណត់ពីបទឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀតទៅហើយ។ ដោយផ្អែកលើធាតុផ្សំនៃភ័ស្តុតាង និងសេចក្តីសន្និដ្ឋានផ្សេងៗទៀតដែលអាចអោយរិះគន់បាន តាមពិតទៅ អង្គជំនុំជម្រះមិនគួរសន្និដ្ឋានថា បុរស "បានទទួលរងគ្រោះពីអំពើហិង្សាផ្លូវភេទដែលផ្ទុយនឹងសេចក្តីថ្លៃថ្នូរជាមនុស្ស"។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះគ្មានជម្រើសអ្វីផ្សេងក្រៅពីសន្និដ្ឋានថា គ្មានភ័ស្តុតាងគ្រប់គ្រាន់អំពីកម្រិតនៃភាពធ្ងន់ធ្ងរដែលដើម្បីអាចកំណត់ថាជាឧក្រិដ្ឋកម្មអមនុស្សធម៌ផ្សេងទៀតបានឡើយ។

១០២. យើងគួររំលឹកនៅពេលនេះថា យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ដែលថាភ័ស្តុតាងប្រយោល និងជាពិសេស មិនពាក់ព័ន្ធ មានតម្លៃជាភ័ស្តុតាងតិចតួច ហើយមិនអាចគាំទ្រដល់ភ័ស្តុតាងផ្ទាល់ដែលគ្មាននោះឡើយ។ ជាក់ស្តែង វាមិនគ្រប់គ្រាន់ទេ ក្នុងការបញ្ចូលធាតុផ្សំភ័ស្តុតាងប្រភេទនេះ ដើម្បីបំពេញបន្ទុកភ័ស្តុតាង ដោយមូលហេតុចំនួនបរិមាណ និងដោយមិនគិតតម្លៃជាភ័ស្តុតាងរបស់វា[146]។ នេះជាអ្វីដែលសហព្រះរាជអាជ្ញាព្យាយាមធ្វើនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន និងជាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើនៅក្នុងសាលក្រមមួយនេះ។

---

[145] សូមមើល ខាងលើ កថាខណ្ឌ ១១-៣៩។

[146] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** កថាខណ្ឌ ៥១៨-៥១៩។

## III. សេចក្ដីសន្និដ្ឋាន

១០៣. **វាមិនអាចទៅរួចទេ ទាំងអង្គហេតុ ទាំងអង្គច្បាប់** ក្នុងការសន្និដ្ឋានថា មានបុរសទទួលរងការឈឺចាប់ធ្ងន់ធ្ងរ ដែលបណ្ដាលមកពីអំពើហិង្សាផ្លូវភេទក្នុងជីវិតគូស្រករ ដើម្បីអាចកំណត់បទឧក្រិដ្ឋក្រោមទម្រង់អំពើអមនុស្សធម៌ផ្សេងទៀត។

១០៤. ទោះបីជាមានមធ្យោបាយធ្វើបណ្ដឹងសាទុក្ខច្រើន ដែលត្រូវរៀបរាប់ពាក់ព័ន្ធនឹងប្រធានបទនៃការរៀបអាពាហ៍ពិពាហ៍ ក្រុមមេធាវីការពារក្ដីសូមកត់សម្គាល់ថា សំអាងហេតុរបស់ម្ចាស់បណ្ដឹងពាក់ព័ន្ធនឹងសាលក្រមជាលាយលក្សណ៍អក្សរនៅក្នុងសំណុំរឿង ០០២/០២ មិនមានមូលដ្ឋានឡើយ។ ទោះបីជាខ្លួនមានថិរវេលារហូតដល់៥ខែហើយក៏ដោយ ក៏សហព្រះរាជអាជ្ញានៅតែគ្មានសមត្ថភាពផ្ដល់អំណះអំណាងដែលមានប្រយោជន៍ដល់សំអាងហេតុនៃបណ្ដឹងសាទុក្ខតែមួយគត់របស់ខ្លួន។

១០៥. **<u>អាស្រ័យហេតុនេះ</u>** មេធាវីការពារក្ដីស្នើសុំតុលាការកំពូលមេត្តា **បដិសេធចោល**បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |